បណ្ណាល័យ
គ.ជ.អ.ប

រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ឯកសារបច្ចេកទេស

## ស្តីពី

## ការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការ អនុវត្តមុខងារជាជម្រើសដោយក្រុមប្រឹក្សា នៃរដ្ឋបាលថ្នាក់ក្រោមជាតិ

354.968 FUN
Sh: Training

លេខាធិការដ្ឋាន គ.ជ.អ.ប
ខែធ្នូ ឆ្នាំ២០១៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខៈ ០៣៤០ [illegible] /គ.ជ.អ.ប

បណ្ណាល័យ
គ.ជ.អ.ប

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ឯកសារបច្ចេកទេសស្តីពី
## ការជ្រើសរើស ការគ្រប់គ្រង ការចាត់តែង និងការអនុវត្ត
## មុខងារជាជម្រើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

## គណៈកម្មាធិការជាតិ
## សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងព្រះរាជក្រមលេខ នស/រកម ០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៥ មាត្រា១៧ និងបន្ថែមមាត្រា១២ស្ទួននៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២៨៥/អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់តែង និងការអនុវត្តមុខងារជាជម្រើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។

បណ្ណាល័យ
គ.ជ.អ.ប

## សម្រេច

**ប្រការ ១.**

ដាក់ឱ្យប្រើប្រាស់នូវឯកសារបច្ចេកទេសស្តីពី "ការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ" ។

**ប្រការ ២.**

ក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល នាយកទីចាត់ការ ប្រធានការិយាល័យ និងមន្ត្រីរាជការទាំងអស់នៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានាត្រូវជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស ដោយអនុវត្តតាមបែបបទ នីតិវិធីដូចបានកំណត់ក្នុងឯកសារបច្ចេកទេសនេះ តាមតម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

**ប្រការ ៣.**

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ មានភារកិច្ចផ្តល់ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសមត្ថភាពគ្រប់គ្រាន់ក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសប្រកបដោយប្រសិទ្ធភាព។

**ប្រការ ៤.**

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*រាជធានីភំពេញ, ថ្ងៃទី..០៤.. ខែ....... ឆ្នាំ២០១៥*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន**

- ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប (ដើម្បីជូនជ្រាប)
- ដូចប្រការ២ និង ប្រការ៣ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ។

# អារម្ភកថា

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបង្កើតឡើងដើម្បីជំរុញ លើកកម្ពស់ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្នុងការអនុវត្តមុខងារ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ ចំពោះប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងត្រូវធានាឱ្យមានតម្លាភាព ប្រសិទ្ធភាព និងការចូលរួមរបស់ប្រជាពលរដ្ឋទាំងស្ត្រី បុរស យុវជន កុមារ ជនពិការ ក្រុមជនងាយរងគ្រោះ រាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ និងជនជាតិដើមភាគតិចនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តរបស់ខ្លួនពាក់ព័ន្ធនឹងការប្រើប្រាស់ និងការកៀរគរធនធានសម្រាប់ផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

ឯកសារបច្ចេកទេសស្តីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស បានរៀបចំឡើងដោយផ្អែកតាមអនុក្រឹត្យស្តីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសដោយក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជួយឱ្យក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ក្នុងការផ្តួចផ្តើមជ្រើសរើស និងអនុវត្តមុខងារជាជម្រើសរបស់ខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការ និងអាទិភាពនៅមូលដ្ឋាន។

ឯកសារបច្ចេកទេសនេះ មិនមែនជាក្របខ័ណ្ឌច្បាប់ ឬជាគោលការណ៍ណែនាំ ដែលតម្រូវឱ្យក្រុមប្រឹក្សាអនុវត្តតាមទាំងស្រុងឡើយ។ ក្រុមប្រឹក្សាអាចប្រើប្រាស់ឯកសារបច្ចេកទេសនេះដោយបត់បែនទៅតាម តម្រូវការជាក់ស្តែងរបស់ខ្លួន និងដើម្បីឆ្លើយតបនឹងស្ថានភាពជាក់ស្តែងនៅមូលដ្ឋានរបស់ខ្លួន។

គណៈកម្មាធិការជាតិសម្រាប់គាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការរួមចំណែកពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធនានាដែលបានផ្តល់មតិយោបល់ និងអនុសាសន៍នានាសម្រាប់រៀបចំឯកសារបច្ចេកទេសនេះ។ ព្រមទាំងសូមថ្លែងអំណរគុណចំពោះកម្មវិធី EU-SPACE ដែលបាន ផ្តល់ការគាំទ្រទាំងបច្ចេកទេស និងថវិកាសម្រាប់ការរៀបចំឯកសារនេះ។ ទន្ទឹមនឹងនេះ គ.ជ.អ.ប សូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះមតិយោបល់ស្ថាបនា ដើម្បីកែលម្អឯកសារបច្ចេកទេសនេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរ។

## មាតិកា


អារម្ភកថា i

សេចក្តីផ្តើម ១

**ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅនៃមុខងារជាជម្រើស**

១.១. និយមន័យ ៣

១.២. ក្របខ័ណ្ឌច្បាប់ ៤

១.៣. ចរិតលក្ខណៈនៃមុខងារជាជម្រើស ៩

១.៤. ការគាំទ្ររបស់អ្នកពាក់ព័ន្ធក្នុងការជ្រើសរើសមុខងារជាជម្រើស ១៥

**ផ្នែកទី២ ៖ ការជ្រើសរើសមុខងារជាជម្រើស**

២.១. ការពិនិត្យមើលអំពីតម្រូវការអាទិភាព ១៧

២.២. ការពិនិត្យមើលអំពីសមត្ថភាព និងធនធាន ២២

២.៣. ការធ្វើសេចក្តីសម្រេចជាបឋម ២៤

២.៤. ការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ២៦

២.៥. ការពិនិត្យអំពីភាពត្រួតគ្នានៃមុខងារ ៣០

២.៦. ការធ្វើសេចក្តីសម្រេចចុងក្រោយ ៣២

**ផ្នែកទី៣ ៖ ការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តមុខងារជាជម្រើស**

៣.១. ការរៀបចំផែនការសកម្មភាព ៣៥

៣.២. ការរៀបចំគម្រោងចំណាយ ៣៧ ៣៧

៣.៣. ការបញ្ចូលផែនការសកម្មភាព និងថវិកាក្នុង
កម្មវិធីវិនិយោគ ៤០

៣.៤. ការរៀបចំគម្រោងថវិកា និងការកែសម្រួលថវិកា ៤១

**ផ្នែកទី៤ ៖ ការអនុវត្តមុខងារជាជម្រើស**

៤.១. ការកំណត់អ្នកពាក់ព័ន្ធ ៤១

៤.២. ការធ្វើលទ្ធកម្ម ៤៧

**ផ្នែកទី៥ ៖ ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តមុខងារជាជម្រើស**

៥.១. អ្នកពាក់ព័ន្ធ ៤៩

៥.២. តួនាទី ភារកិច្ច ៥០

**ផ្នែកទី៦ ៖ បទពិសោធន៍នៃការអនុវត្តមុខងារជាជម្រើស**

៦.១. បទពិសោធន៍១ ៖ ការគ្រប់គ្រងសត្វពាហនៈ ៥៤

៦.២. បទពិសោធន៍២ ៖ ការរៀបចំសណ្តាប់ធ្នាប់ផ្សារ ៥៦

ឧបសម្ព័ន្ធ ៖ អនុក្រឹត្យលេខ ២៨៥ អនក្រ.បក ៥៨

# សេចក្ដីផ្ដើម

ឯកសារបច្ចេកទេសស្ដីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសត្រូវបានតាក់តែងឡើងក្នុងគោលបំណងជួយបង្កលក្ខណៈងាយស្រួលសម្រាប់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ក្នុងការផ្ដួចផ្ដើមជ្រើសរើស ការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តមុខងារជាជម្រើស និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងារទាំងនោះ។

ឯកសារបច្ចេកទេសនេះ ត្រូវបានចងក្រងដោយផ្ដោតលើខ្លឹមសារជាការចង្អុលបង្ហាញអំពីដំណើរការនៃការជ្រើសរើស ការចាត់ចែង និងការអនុវត្តសកម្មភាពអាទិភាពចាំបាច់នានា ដែលជាតម្រូវការចំពោះមុខរបស់មូលដ្ឋាន ដោយមានការសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធនានា។ ឯកសារបច្ចេកទេសនេះ បានចងក្រងឡើងផ្អែកលើមូលដ្ឋាននៃអនុក្រឹត្យលេខ ២៨៥អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ ស្ដីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្របតាមក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

ឯកសារបច្ចេកទេសនេះ ចែកចេញជា ៦ ផ្នែករួមមាន៖

- <u>ផ្នែកទី១៖</u> បង្ហាញពីក្របខណ្ឌច្បាប់ពាក់ព័ន្ធនានា អត្ថន័យ

និងចរិតលក្ខណៈ នៃមុខងារជាជម្រើស។

- **<u>ផ្នែកទី២ ដល់ ទី៥</u> ៖** បង្ហាញពីកិច្ចការដែលរដ្ឋបាលថ្នាក់ក្រោមជាតិគួរពិចារណាក្នុងការកំណត់ ការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស ព្រមទាំងបានបង្ហាញលម្អិតអំពីការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តមុខងារជាជម្រើសនៅក្នុងមូលដ្ឋានរបស់ខ្លួន។
- **<u>ផ្នែកទី៦</u> ៖** បង្ហាញពីបទពិសោធន៍ទាក់ទងនឹងមុខងារជាជម្រើសដែលធ្លាប់បានអនុវត្តនៅប្រទេសកម្ពុជា។

ឯកសារបច្ចេកទេសនេះ មិនជំនួសឱ្យគោលការណ៍ណែនាំដែលមានស្រាប់ទាក់ទងនឹងការកសាងផែនការ ការរៀបចំផែនការថវិកា កិច្ចការលទ្ធកម្ម និងការរៀបចំគម្រោងឡើយ ប៉ុន្តែរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាអាចប្រើប្រាស់ឯកសារបច្ចេកទេសនេះឱ្យស្របជាមួយនឹងគោលការណ៍ណែនាំទាំងនោះ។

# ផ្នែកទី ១
# ទិដ្ឋភាពទូទៅនៃមុខងារជាជម្រើស

ផ្នែកទី១ "ទិដ្ឋភាពទូទៅនៃមុខងារជាជម្រើស"នេះ បង្ហាញអំពីទិដ្ឋភាពទូទៅនៃមុខងារជាជម្រើស ដែលផ្តួចផ្តើមជ្រើសរើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តមុខងារជាជម្រើសរបស់ខ្លួន។ ផ្នែកនេះក៏បង្ហាញអំពីនិយមន័យ ក្របខណ្ឌច្បាប់ ចរិតលក្ខណៈនៃមុខងារជាជម្រើស និងការគាំទ្ររបស់អ្នកពាក់ព័ន្ធនានា ក្នុងការអនុវត្តមុខងារជាជម្រើស។

## ១.១.និយមន័យ

មុខងារជាជម្រើស គឺជាមុខងារទាំងឡាយដែលត្រូវបានផ្តួចផ្តើមជ្រើសរើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងក្របខណ្ឌនៃអនុក្រឹត្យស្តីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

មុខងារជាជម្រើសមានពីរប្រភេទរួមមាន ៖

- **ប្រភេទទី១៖** មុខងារទាំងឡាយដែលមិនស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល។
- **ប្រភេទទី២ ៖** មុខងារទាំងឡាយដែលស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល ប៉ុន្តែក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់

ព័ន្ធពុំជំទាស់ចំពោះ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការជ្រើសរើសយកមកអនុវត្តនូវមុខងារទាំងនោះ។

## ១.២.ក្របខ័ណ្ឌច្បាប់

ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា ដែលបានផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សា ក្នុងការអនុវត្តមុខងារជាជម្រើសរួមមាន ៖

### ១.២.១).ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ ដូចខាងក្រោម ៖

- ក្រុមប្រឹក្សាត្រូវគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសក្នុងកម្រិតអតិបរមានៃលទ្ធភាព និងធនធានដែលខ្លួនមាន
- ក្រុមប្រឹក្សាមានសិទ្ធិធ្វើសេចក្តីសម្រេចទៅលើរបៀបគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសដោយអនុលោមតាមបទដ្ឋាន និងនីតិវិធីដែលមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- ក្រុមប្រឹក្សាមានសិទ្ធិសម្រេចដោយឆន្ទានុសិទ្ធិផ្ទាល់របស់ខ្លួនក្នុងការកំណត់បទដ្ឋាន នីតិវិធី និងធនធានសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស ចំពោះមុខងារជាជម្រើសដែលមិនធ្លាប់បានគ្រប់គ្រង ចាត់ចែង និងអនុវត្តពីមុនដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល។

### ១.២.២). ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាល

បណ្ណាល័យ
គ.ជ.អ.ប

ថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគ្រប់គ្រង និងប្រើប្រាស់ថវិកាប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះរាជរដ្ឋាភិបាល រួមទាំងការចំណាយក្នុងការអនុវត្តមុខងារជាជម្រើស (មាត្រា២២ និងមាត្រា២៣)។

**១.២.៣). អនុក្រឹត្យស្តីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្ត មុខងារជាជម្រើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ**

- ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចផ្តួចផ្តើមជ្រើសរើសមុខងារជាជម្រើសមកអនុវត្ត ដោយផ្អែកលើតម្រូវការរបស់ប្រជាពលរដ្ឋ ឬអាទិភាពនៃមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងផ្អែកទៅតាមសមត្ថភាពផ្នែករដ្ឋបាលបច្ចេកទេស និងហិរញ្ញវត្ថុដែលខ្លួនមាន (មាត្រា៩)។
- ក្នុងការជ្រើសរើសមុខងារជាជម្រើស ក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទដូចគ្នា និង ឬប្រភេទ ផ្សេងគ្នាដែលពាក់ព័ន្ធតាមការចាំបាច់។
- ការសម្រេចយកមុខងារជាជម្រើសណាមួយ ឬមួយចំនួនមកអនុវត្ត ត្រូវមានការអនុម័តពីក្រុមប្រឹក្សា។
- ចំពោះការសម្រេចយកមុខងារជាជម្រើសណាមួយ ឬមួយចំនួនដែលស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័នមន្ទីរ អង្គភាពជំនាញ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្របសម្រួល និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន

មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធទាំងនោះ មុននឹងក្រុមប្រឹក្សាអនុម័ត។

- ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសដោយខ្លួនឯងផ្ទាល់ ឬដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ឬក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ ឬដោយសហការជាមួយផ្នែកឯកជន ឬសង្គមស៊ីវិល ឬអ្នកពាក់ព័ន្ធ
- អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនត្រូវធានាអនុវត្តនូវមុខងារជាជម្រើស ដែលបានអនុម័តដោយក្រុមប្រឹក្សាឱ្យមានប្រសិទ្ធភាព។
- ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចាត់ចែងឱ្យមានការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស។
- អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវរាយការណ៍អំពីលទ្ធផលនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសជូនក្រុមប្រឹក្សារបស់ខ្លួន។
- បទដ្ឋាន នីតិវិធី និងធនធានសម្រាប់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសត្រូវសម្រេចដោយឆន្ទានុសិទ្ធិផ្ទាល់របស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។
- ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស

ត្រូវផ្អែកលើគោលការណ៍ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ការពិគ្រោះយោបល់ ការចូលរួម និងសមធម៌។

- មុខងារជាជម្រើសណាមួយ ឬមួយចំនួន ដែលក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានបំណងជ្រើសរើសយកមកអនុវត្ត ចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលសាមីនីមួយៗ។
- ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចធ្វើការកែសម្រួលនូវកម្មវិធីវិនិយោគរបស់ខ្លួន ដើម្បីដាក់បញ្ចូលនូវមុខងារជាជម្រើសថ្មី ឬមុខងារជាជម្រើសដែលត្រូវកែសម្រួល ដោយផ្អែកលើសំណូមពរ និងតម្រូវការចាំបាច់របស់មូលដ្ឋាន។ (មាត្រា ៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១២ មាត្រា១៨)។

### ១.២.៤). អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅមូលនិធិក្រុង ស្រុក

អនុក្រឹត្យនេះ ផ្តល់លទ្ធភាពដល់ការគ្រប់គ្រងមូលនិធិក្រុង ស្រុក ក្នុងការផ្តល់មូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌពីថវិកាជាតិ និងពីប្រភពផ្សេងៗទៀត សម្រាប់រួមចំណែកក្នុងការអនុវត្តចំណាយបម្រើឱ្យសកម្មភាពទាំងឡាយ រួមទាំងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសនានា (មាត្រា៣)។

### ១.២.៥). អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក

ការប្រើប្រាស់មូលនិធិក្រុង ស្រុក គឺដើម្បីសម្រេចបាននូវការបង្កើត ការជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងធ្វើប្រតិ

ភូកម្ម។ អភិបាលនៃគណៈអភិបាលក្រុង ស្រុកក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវគម្រោងថវិកាយ៉ាងតិចមួយសប្ដាហ៍ មុនពេលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ដើម្បីប្រមូលយោបល់ចូលរួមនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន (មាត្រា១៥)។

### ១.២.៦). អនុក្រឹត្យស្ដីពីតួនាទីភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ

រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្ដីសម្រេចខាងប្រតិបត្តិដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលរាជធានី និងវិធានការ បែបបទនីតិវិធីចាត់ចែងការងារតាមការចាំបាច់ ដែលទាក់ទងទៅនឹងការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សារាជធានី (មាត្រា១៤)។

### ១.២.៧). អនុក្រឹត្យស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាខេត្តត្រូវធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្ដីសម្រេចខាងប្រតិបត្តិ ដែលជាគោលការណ៍ គោលនយោបាយរបស់ខេត្ត និងវិធានការ បែបបទ នីតិវិធីចាត់ចែងការងារតាមការចាំបាច់ ដែលទាក់ទងទៅនឹងការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក (មាត្រា១៤ មាត្រា៧០ មាត្រា ១៣២)។

### ១.២.៨). អនុក្រឹត្យស្ដីពីមូលនិធិ ឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់ថវិកាផ្ទេរពីមូលនិធិឃុំ សង្កាត់ សម្រាប់ចំណាយមួយផ្នែក ឬទាំងស្រុងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន និងការផ្តល់សេវាសេដ្ឋកិច្ចសង្គមនៅឃុំ សង្កាត់ ដែលឆ្លុះបញ្ចាំងនៅក្នុងថវិកាដែលបានអនុម័តដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងមិនផ្ទុយទៅនឹងច្បាប់ និងលិខិតបទដ្ឋានទាំងឡាយជាធរមាន (មាត្រា១៥)។

**១.២.៩). អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់**

ថវិកាឃុំ សង្កាត់ត្រូវរាប់បញ្ចូលរាល់ចំណូល ចំណាយរបស់ឃុំ សង្កាត់ដោយមិនគិតដល់ប្រភពដើម ឬចរិតលក្ខណៈឡើយ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងរាល់ការចំណាយជាអាទិភាពនៃផែនការអភិវឌ្ឍរបស់ឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់ថវិការបស់ឃុំ សង្កាត់ទៅលើការចំណាយវិនិយោគអភិវឌ្ឍមូលដ្ឋាន ចំណាយសេវាសាធារណៈ ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ច និងចំណាយមិនបានគ្រោងទុក (មាត្រា៣ ដល់៧)។

## ១.៣. ចរិតលក្ខណៈនៃមុខងារជាជម្រើស

មុខងារជាជម្រើសនៅក្នុងឯកសារបច្ចេកទេសនេះ គឺសំដៅទៅលើមុខងារដែលជ្រើសរើស តាមគំនិតផ្តួចផ្តើមរបស់ក្រុមប្រឹក្សា។ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានឆន្ទានុសិទ្ធិយ៉ាងពេញលេញក្នុងការជ្រើសរើសយកមុខងារជាជម្រើស ដើម្បីឆ្លើយតបនឹងសំណូមពរ និងតម្រូវការរបស់មូលដ្ឋាន។

មុខងារជាជម្រើសនៅក្នុងឯកសារបច្ចេកទេសនេះ មានចរិតលក្ខណៈដូចខាងក្រោម ៖

- ជាមុខងារដែលផ្ដើមចេញពីគំនិតផ្ដួចផ្ដើមរបស់ក្រុមប្រឹក្សាតាមរយៈវិធីសាស្ត្រផ្សេងៗ
- មិនមែនជាមុខងារជាជម្រើសដែលក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល បានផ្ទេរឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តនោះឡើយ
- ជាមុខងារដែលក្រុមប្រឹក្សាប្រភេទផ្សេងគ្នា ឬប្រភេទដូចគ្នាអាចជ្រើសរើសយកមកអនុវត្តមុខងារតែមួយដូចគ្នា
- ជាមុខងារដែលអាចប្រែប្រួលទៅតាមពេលវេលា និងស្ថានភាព ហើយក្រុមប្រឹក្សាអាចបញ្ចប់មុខងារទាំងនោះតាមការចាំបាច់
- ជាមុខងារដែលមិនត្រូវការចំណាយ ឬត្រូវការចំណាយតិចតួច ឬត្រូវការចំណាយច្រើន
- ប្រើប្រាស់ថវិកា ឬមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ (ជាមូលនិធិ ដែលក្រុមប្រឹក្សាទទួលពីថ្នាក់ជាតិ និងពីប្រភពផ្សេងៗទៀត ដែលមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តនានា)

បទដ្ឋាន នីតិវិធី និងធនធានដែលត្រូវការចាំបាច់សម្រាប់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសជាឆន្ទានុសិទ្ធិផ្ទាល់របស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិជាអ្នកកំណត់។

**ឧទាហរណ៍** ៖ ក្រុមប្រឹក្សាជ្រើសរើសយកមុខងារក្នុងការបង្កើតមត្តេយ្យ

សហគមន៍។ ដើម្បីអនុវត្តមុខងារនេះ ក្រុមប្រឹក្សាអាចកំណត់ចំនួនថវិកា ចំនួនម៉ោងទទួលថែទាំកុមារតូច លក្ខណៈសម្បត្តិរបស់លោកគ្រូ អ្នកគ្រូ និងបទដ្ឋានផ្សេងទៀតទាក់ទងនឹងទីតាំងរបស់មត្តេយ្យសហគមន៍។

នៅក្នុងការអនុវត្តមុខងារជាជម្រើស ក្រុមប្រឹក្សាគួរយកចិត្តទុកដាក់ក្នុងការកំណត់ និងជ្រើសរើសមុខងារណាដែលផ្តោតលើសកម្មភាពផ្តល់សេវាឱ្យបានច្រើនជាអតិបរមា ជាជាងការផ្តោតទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ មូលហេតុដែលត្រូវផ្តោតការយកចិត្តទុកដាក់លើមុខងារសេវាដោយសារតែមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌមានទំហំតិចតួចនៅឡើយ។ ម្យ៉ាងទៀត សកម្មភាពផ្តល់សេវា អាចមានភាពងាយស្រួលក្នុងការប្រើប្រាស់ជាចំណាយចរន្ត។

**ឧទាហរណ៍ ៖**

- សកម្មភាពផ្សព្វផ្សាយសុខភាពជាប្រចាំ គឺក្រុមប្រឹក្សាអាចចំណាយចរន្តលើប្រាក់ឧបត្ថម្ភ សម្រាប់បុគ្គលិកកិច្ចសន្យាផ្នែកសុខាភិបាល ឯកសារផ្សព្វផ្សាយ ការចំណាយលើការធ្វើដំណើរ និងការចំណាយលើការរៀបចំព្រឹត្តិការណ៍។ សកម្មភាពផ្តល់សេវា ក៏អាចជាការចំណាយមូលធន និងការចំណាយចរន្តផងដែរ។
- សកម្មភាពអប់រំកុមារតូចតម្រូវឱ្យមានការចំណាយមូលធនទៅលើបន្ទប់រៀន និងឧបករណ៍នៅក្នុងបន្ទប់រៀន ក៏ដូចជាការចំណាយចរន្តលើប្រាក់ខែគ្រូបង្រៀនផងដែរ។

ជាទូទៅ មុខងារជាជម្រើសដែលទាក់ទងនឹងសកម្មភាពផ្តល់សេវាតម្រូវឱ្យមានការគាំទ្របច្ចេកទេស ការយល់ព្រម ឬការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល។

ខាងក្រោមនេះ ជាឧទាហរណ៍នៃមុខងារជាជម្រើសមួយចំនួន សម្រាប់ជាជំនួយស្មារតី ដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សាអាចផ្តួចផ្តើមនូវមុខងារជាជម្រើសខុសៗគ្នាទៅតាមស្ថានភាពភូមិសាស្ត្រ សេដ្ឋកិច្ច និងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន។

| **ផ្នែកសុខាភិបាល** |
| --- |
| • ការផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងអំពីសុខភាពសម្រាប់ក្រុមគោលដៅឬសម្រាប់បញ្ហាសុខភាពណាមួយ (ឧទាហរណ៍៖ សុខភាពបន្តពូជ HIV/AIDs គ្រុនចាញ់ ការថែទាំអនាម័យ ...)<br>• ការផ្តល់មធ្យោបាយក្នុងការបញ្ជូនអ្នកជំងឺទៅទទួលសេវាសុខភាព<br>• ...។ល។ |
| **ផ្នែកអប់រំ** |
| • ការជួលគ្រូសម្រាប់មត្តេយ្យសិក្សាសហគមន៍<br>• ការចាត់ចែងការអប់រំកុមារតូច<br>• ការរៀបចំបណ្ណាល័យសហគមន៍<br>• ការបង្កើត និងចាត់ចែងថ្នាក់អក្ខរកម្ម<br>• ការផ្តល់សម្ភារៈសិក្សាសម្រាប់កុមារក្រីក្រ<br>• ...។ល។ |
| **ផ្នែកសង្គមកិច្ច** |
| • ការផ្តល់ការគាំទ្រដល់ជនក្រីក្រនិងជនងាយរងគ្រោះ<br>• ការបង្កើតសួនកុមារ<br>• ការកសាងឈាបនដ្ឋានសម្រាប់បូជាសព<br>• ...។ល។ |

| ផ្នែកអភិវឌ្ឍន៍ជនបទ |
|---|
| • គាំទ្រសកម្មភាពពាក់ព័ន្ធការលើកកម្ពស់អនាម័យជនបទ<br>• គាំទ្រការចងក្រងក្រុមកសិករ<br>• គាំទ្រការបង្កើតមជ្ឈមណ្ឌលសហគមន៍ (កន្លែងសម្រាប់ជួបជុំរបស់ប្រជាពលរដ្ឋក្នុងភូមិឃុំ)<br>• ការស្តារស្រះទឹកនៅតាមសហគមន៍<br>• ...។ល។ |
| **ផ្នែកវប្បធម៌វិចិត្រសិល្បៈកីឡា និងសាសនា** |
| • សកម្មភាពខាងផ្នែកវប្បធម៌(សកម្មភាពអភិរក្សល្បែងប្រជាប្រិយ ការប្រកួតប្រជែងធ្វើម្ហូប ការប្រលងចំរៀងបុរាណ ...)<br>• ការរៀបចំទីលានកីឡាសម្រាប់សហគមន៍<br>• ការផ្តល់សម្ភារៈកីឡាសម្រាប់សហគមន៍<br>• ...។ល។ |
| **ផ្នែកសេដ្ឋកិច្ច** |
| • ការលើកកម្ពស់ការអភិវឌ្ឍទេសចរណ៍ធម្មជាតិដូចជាការរៀបចំអនាម័យនៅតំបន់ទេសចរណ៍ការអភិរក្សបឹងធម្មជាតិ...។ល។<br>• ការពង្រឹងសមត្ថភាពរបស់ក្រុមគោលដៅ (**ឧទាហរណ៍៖** កសិករ អាជីវករ និងសហគ្រិនជាស្ត្រី)<br>• ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម<br>• ការបណ្តុះបណ្តាលស្តីពីសិប្បកម្មខ្នាតតូចដល់ក្រុមស្ត្រី<br>• ...។ល។ |
| **ផ្នែកគ្រប់គ្រងគ្រោះមហន្តរាយ** |
| • ការត្រៀមវិធានការឆ្លើយតបចំពោះគ្រោះមហន្តរាយ (ឧទាហរណ៍៖ ការ |

| |
|---|
| ត្រៀមទុកនៅរដូវទឹកជំនន់ ការត្រៀមទីទួលសុវត្ថិភាព ការត្រៀមបង្ការ និងការពន្លត់អគ្គីភ័យ<br>• ...។ល។ |
| **ផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ** |
| • ការងារទាក់ទងផ្លូវថ្នល់ (ឧទាហរណ៍៖ ការជួសជុល និងថែទាំផ្លូវគ្រួសក្រហមក្នុងភូមិ ឃុំ...)<br>• ការងារទាក់ទងនឹងស្ពាន (ការជួសជុល និងថែទាំស្ពានក្នុងភូមិ ឃុំ)<br>• ...។ល។ |
| **ផ្នែកផ្សេងៗ** |
| • ការរៀបចំបទបញ្ញត្តិនានាសម្រាប់មូលដ្ឋាន<br>• ការសំអាតផ្លូវ ការប្រមូលសំរាមតាមទីសាធារណៈ<br>• យុទ្ធនាការបរិស្ថានតាមមូលដ្ឋាន<br>• ការរៀបចំទីធ្លាសម្រាប់កុមារក្នុងសហគមន៍<br>• ការអនុវត្តសកម្មភាពនានាពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ<br>• ...។ល។ |

**កំណត់សម្គាល់៖**

- ក្នុងការជ្រើសរើសមុខងារជាជម្រើស ក្រុមប្រឹក្សាគួរជ្រើសរើសមុខងារជាជម្រើសណាដែលសមស្របទៅនឹងធនធាន និងសមត្ថភាពគ្រប់គ្រងរបស់ខ្លួន
- ជាការប្រសើរក្រុមប្រឹក្សា គួរជ្រើសរើសមុខងារជាជម្រើសណាមួយដែលមិនត្រូវការការចំណាយច្រើន ដែលការធ្វើដូចនេះអាចឱ្យក្រុមប្រឹក្សាទទួលបានបទពិសោធន៍ និងចៀសវាង

ចំណាយមូលនិធិទាំងអស់ទៅលើមុខងារជាជម្រើសក្នុងការផ្តល់សេវាមួយ ដែលមានទំហំធំ និងមានលក្ខណៈជារូបវន្តស្ទើរតែទាំងស្រុង (ដូចជាការជីកប្រឡាយទឹកជាគម្រោងដែលចំណាយច្រើន)។

## ១. ៤. ការគាំទ្ររបស់អ្នកពាក់ព័ន្ធក្នុងការជ្រើសរើសមុខងារជាជម្រើស

នៅពេលក្រុមប្រឹក្សាកំណត់ និងជ្រើសរើសមុខងារជាជម្រើសដែលបានផ្តួចផ្តើមរួចហើយ ក្រុមប្រឹក្សាត្រូវ<u>សម្របសម្រួលជាមុន</u>ជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានាមុនពេលក្រុមប្រឹក្សាចាប់ផ្តើមកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ខ្លួន ប្រសិនបើក្រុមប្រឹក្សាយល់ឃើញថា មុខងារជាជម្រើសរើសណាមួយដែលអាចជាប់ពាក់ព័ន្ធជាមួយនឹងមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានា ។

**កំណត់សម្គាល់៖**

- ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចណែនាំគណៈអភិបាលរបស់ខ្លួន ដើម្បីស្នើសុំឱ្យមានការគាំទ្រ និងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានាលើមុខងារជាជម្រើសដែលខ្លួនជ្រើសរើស ឬ
- ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាចស្នើសុំអភិបាលរាជធានី ខេត្ត ដើម្បីគាំទ្រ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលក្នុងការជ្រើសរើសមុខងារជាជម្រើសមកអនុវត្ត

- ក្រុមប្រឹក្សាឃុំ សង្កាត់ អាចណែនាំមេឃុំ ចៅសង្កាត់របស់ខ្លួន ដើម្បីស្នើសុំឱ្យមានការគាំទ្រ និងការសម្របសម្រួលជាមួយ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានាលើមុខងារជា ជម្រើសដែលខ្លួនជ្រើសរើស ឬ
- ក្រុមប្រឹក្សាឃុំ សង្កាត់អាចស្នើសុំអភិបាល រាជធានី ខេត្តឱ្យមាន ការគាំទ្រ និងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានា លើមុខងារជាជម្រើសដែលខ្លួនជ្រើស រើស។

## ផ្នែកទី២

## ការជ្រើសរើសមុខងារជាជម្រើស

ផ្នែកទី២ "ការជ្រើសរើសមុខងារជាជម្រើស" នឹងបង្ហាញអំពីដំណើរការក្នុងការជ្រើសរើសមុខងារជាជម្រើស ព្រមទាំងបង្ហាញពីតួនាទីរបស់អ្នកពាក់ព័ន្ធនានា ដើម្បីឱ្យក្រុមប្រឹក្សាពិចារណាក្នុងការផ្តួចផ្តើមជ្រើសរើសមុខងារជាជម្រើស។

ក្នុងការកំណត់ និងជ្រើសរើសមុខងារជាជម្រើស ក្រុមប្រឹក្សាគួរពិចារណាលើកិច្ចការមួយចំនួនដូចខាងក្រោម ៖

១. ការពិនិត្យមើលអំពីតម្រូវការអាទិភាពរបស់មូលដ្ឋាន
២. ការពិនិត្យមើលអំពីធនធាន និងសមត្ថភាពរបស់ខ្លួនក្នុងការគ្រប់គ្រងមុខងារជាជម្រើស
៣. ការធ្វើសេចក្តីសម្រេចជាបឋម អំពីមុខងារជាជម្រើសដែលត្រូវជ្រើសរើស
៤. សម្របសម្រួលជាមួយក្រសួង ស្ថាប័ន ឬក្រុមប្រឹក្សាផ្សេងទៀត
៥. ការពិនិត្យមើលពីការត្រួតស៊ីគ្នានៃការជ្រើសរើសមុខងារជាជម្រើស
៦. ការធ្វើសេចក្តីសម្រេចចុងក្រោយអំពីការជ្រើសរើសមុខងារជាជម្រើស។

### ២.១. ការពិនិត្យមើលអំពីតម្រូវការអាទិភាពរបស់មូលដ្ឋាន

អ្នកពាក់ព័ន្ធក្នុងការពិនិត្យមើលអំពីតម្រូវការអាទិភាពរបស់មូលដ្ឋាន រួមមាន៖

- ក្រុមប្រឹក្សា
- គណៈអភិបាល
- គណៈកម្មាធិការពាក់ព័ន្ធរបស់ក្រុមប្រឹក្សា
- អង្គភាពពាក់ព័ន្ធនានា
- មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង។

នៅពេលក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្តួចផ្តើមកំណត់រកមុខងារជាជម្រើសណាមួយ ក្រុមប្រឹក្សាត្រូវណែនាំគណៈអភិបាល អង្គភាពពាក់ព័ន្ធ និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សា ដើម្បីសិក្សាលើកិច្ចការនេះ។ បន្ទាប់មក អ្នកដែលត្រូវបានចាត់តាំង ត្រូវរាយការណ៍ និងលើកយោបល់ជូនក្រុមប្រឹក្សាអំពីលទ្ធផលនៃការសិក្សានោះ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ណែនាំមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ដើម្បីសិក្សាលើកិច្ចការនេះ បន្ទាប់មកត្រូវរាយការណ៍ និងផ្តល់អនុសាសន៍ ជូនក្រុមប្រឹក្សាអំពីលទ្ធផលនៃការសិក្សានោះ។

ដើម្បីធ្វើការសិក្សា និងលើកយោបល់ជូនក្រុមប្រឹក្សា គណៈអភិបាល អង្គភាពពាក់ព័ន្ធ និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សា មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង គួរពិចារណានូវចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

### ២.១.១. ការសិក្សាអំពីសេវាដែលប្រជាពលរដ្ឋត្រូវការ

សេវាទាំងនោះអាចជាសេវា ដែលមិនទាន់ផ្តល់នៅឡើយនៅមូលដ្ឋាន ឬអាចជាសេវាដែលកំពុងផ្តល់ដោយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ឬដោយក្រុមប្រឹក្សាណាមួយ ប៉ុន្តែការផ្តល់សេវាទាំងនោះនៅមិនទាន់មានលក្ខណៈពេញលេញ ឬគ្រប់គ្រាន់នៅឡើយ។ គណៈ

អភិបាល អង្គភាពពាក់ព័ន្ធ និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សា មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងត្រូវប្រមូលព័ត៌មានអំពីសេវាដែលប្រជាពលរដ្ឋត្រូវការតាមវិធីសាស្ត្រដូចខាងក្រោមនេះ៖

- ព័ត៌មានដែលប្រមូលបាននៅក្នុងអំឡុងពេលនៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងព្រឹត្តិការណ៍ផ្សេងៗដែលរៀបចំដោយក្រុមប្រឹក្សា
- ព័ត៌មានដែលប្រមូលបាននៅក្នុងអំឡុងពេលនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់
- ព័ត៌មានដែលប្រមូលបាននៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
- ព័ត៌មានដែលប្រមូលបាននៅក្នុងអំឡុងពេលនៃដំណើរការកសាងផែនការ
- ប្រភពព័ត៌មានផ្សេងទៀតដែលមាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងការសិក្សា និងកំណត់អំពីមុខងារជាជម្រើសនេះ សមាជិកក្រុមប្រឹក្សា ប្រជាពលរដ្ឋ និងសង្គមស៊ីវិលមានសិទ្ធិលើកសំណើអំពីមុខងារជាជម្រើស។ មធ្យោបាយដែលសមាជិកក្រុមប្រឹក្សា ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលអាចប្រើប្រាស់សិទ្ធិរបស់ខ្លួន អាចមានដូចជា ៖

- **សម្រាប់សមាជិកក្រុមប្រឹក្សា** ៖ សមាជិកក្រុមប្រឹក្សាគ្រប់រូបមានសិទ្ធិស្នើនូវមុខងារជាជម្រើស សម្រាប់ក្រុមប្រឹក្សាធ្វើការពិចារណា។ សមាជិកក្រុមប្រឹក្សាអាចស្នើឡើងតាមរយៈប្រធានក្រុមប្រឹក្សា គណៈអភិបាល ឬប្រធានគណៈកម្មាធិការណាមួយរបស់ក្រុមប្រឹក្សា។ សមាជិកក្រុមប្រឹក្សា

ក៏អាចស្នើដាក់បញ្ចូលសំណើនេះនៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា (សូមពិនិត្យមើលនីតិវិធីនៃការរៀបចំសេចក្តីព្រាងរបៀបវារៈកិច្ចប្រជុំ ក្នុងឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា)។

- **សម្រាប់ប្រជាពលរដ្ឋ និងសង្គមស៊ីវិល ៖** ប្រជាពលរដ្ឋនិងសង្គមស៊ីវិលមានសិទ្ធិលើកសំណើមុខងារជាជម្រើសទៅក្រុមប្រឹក្សាសម្រាប់ពិចារណាតាមរយៈប្រធានក្រុមប្រឹក្សា គណៈអភិបាល មេឃុំ ចៅសង្កាត់ ឬគណៈកម្មាធិការណាមួយរបស់ក្រុមប្រឹក្សា ឬមេភូមិ ឬគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ។ ប្រជាពលរដ្ឋ ឬ តំណាងសង្គមស៊ីវិលអាចចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងមានមតិយោបល់លើសំណើនេះ។ ប្រជាពលរដ្ឋ និងសង្គមស៊ីវិល ក៏អាចលើកជាសំណើនូវមុខងារជាជម្រើសនៅក្នុងអំឡុងពេលនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះ យោបល់ក្នុងសកម្មភាពចូលរួមរបស់ប្រជាពលរដ្ឋ និងក្នុងដំណើរការកសាងផែនការរបស់ក្រុមប្រឹក្សា។

### ២.១.២. ការពិនិត្យមើលអំពីឆន្ទៈ និងលទ្ធភាពនៃការចូលរួមចំណែករបស់ប្រជាពលរដ្ឋជាមួយក្រុមប្រឹក្សាក្នុងការផ្តល់សេវា

មុនពេលជ្រើសរើសមុខងារជាជម្រើសក្រុមប្រឹក្សាត្រូវពិចារណាអំពីលទ្ធភាព និងឆន្ទៈរបស់ប្រជាពលរដ្ឋដើម្បីចូលរួមចំណែកក្នុងការអនុវត្តមុខងារជាជម្រើសទាំងនោះ។

**ឧទាហរណ៍៖**

- ការចូលរួមចំណែកផ្តល់បដិភាគរបស់មាតា បិតា ចំពោះ

ការចំណាយលើការអប់រំកុមារតូច។

- ប្រជាពលរដ្ឋមានឆន្ទៈ និងលទ្ធភាពចូលរួមចំណែកលើការចំណាយលើតម្លៃមុងការពារជម្ងឺគ្រុនចាញ់។

### ២.១.៣. ផ្តល់ផលប្រយោជន៍ច្រើនដល់ប្រជាពលរដ្ឋ

មុខងារជាជម្រើសដែលក្រុមប្រឹក្សាជ្រើសរើស គួរផ្អែកទៅលើតម្រូវការរបស់ប្រជាពលរដ្ឋភាគច្រើន។ ការផ្តល់សេវា ត្រូវគិតដល់ផលប្រយោជន៍មនុស្សភាគច្រើន ជាជាងផ្តល់សេវាតែទៅលើបុគ្គលមានឥទ្ធិពលតែម្នាក់ ឬមួយក្រុមតូច ហើយចំណាយថវិកាច្រើនពេក ដែលមិនចាំបាច់ក្នុងការទទួលសេវា។ ដូច្នេះ ការផ្តល់សេវានេះ ត្រូវគិតអំពីអាទិភាពចាំបាច់សម្រាប់អ្នកទទួលសេវា។

ក្រៅពីការពិចារណាផ្តល់សេវាដល់ប្រជាពលរដ្ឋភាគច្រើន ក្រុមប្រឹក្សាត្រូវពិចារណានូវតម្រូវការអាទិភាពចាំបាច់ ឬបន្ទាន់ ទោះបីអ្នកទទួលផលប្រយោជន៍ពីសេវានេះមានចំនួនតិចក៏ដោយ ជាពិសេសតម្រូវការរបស់ស្ត្រី យុវជន កុមារ និងជនងាយរងគ្រោះ។

**ឧទាហរណ៍** ៖ ក្រុមប្រឹក្សាពិនិត្យមើលអំពីភាពខ្វះខាតទឹកស្អាតរបស់ប្រជាពលរដ្ឋចំនួន២០គ្រួសារ។ ដូច្នេះ ក្រុមប្រឹក្សាគួរពិចារណាអំពីការបង្កើតឱ្យមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋទាំងនេះ ជាជាងការបង្កើតសួនកុមារដែលបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ១០០គ្រួសារ។

បន្ទាប់ពីបានពិនិត្យមើលលក្ខណៈវិនិច្ឆ័យ គណៈអភិបាល គណៈកម្មាធិការរបស់ក្រុមប្រឹក្សា មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងអង្គភាពពាក់ព័ន្ធណាមួយ គួរកត់ត្រាមតិយោបល់ និងអនុសាសន៍

នានា ដើម្បីជម្រាបជូនក្រុមប្រឹក្សានៅក្នុងអំឡុងពេលនៃកិច្ចប្រជុំសាមញ្ញ ឬកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា។

## ២.២. ការពិនិត្យមើលអំពីសមត្ថភាព និងធនធានរបស់ក្រុមប្រឹក្សាក្នុងការគ្រប់គ្រងមុខងារជាជម្រើស

អ្នកពាក់ព័ន្ធក្នុងការពិនិត្យមើលអំពីសមត្ថភាព និងធនធានរបស់ក្រុមប្រឹក្សាក្នុងការគ្រប់គ្រងមុខងារជាជម្រើស រួមមាន៖

- ក្រុមប្រឹក្សា
- គណៈអភិបាល
- គណៈកម្មាធិការណាមួយរបស់ក្រុមប្រឹក្សា
- អង្គភាពពាក់ព័ន្ធណាមួយ
- មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង

បន្ទាប់ពីបានពិនិត្យមើលអំពីតម្រូវការអាទិភាព និងការចូលរួមចំណែករបស់ប្រជាពលរដ្ឋ ដើម្បីកំណត់មុខងារជាជម្រើសគណៈអភិបាល អង្គភាពពាក់ព័ន្ធ គណៈកម្មាធិការណាមួយ មេឃុំ ចៅសង្កាត់ គួរពិចារណានូវចំណុចសំខាន់ៗដូចខាងក្រោម៖

### ២.២.១. សមត្ថភាពក្រុមប្រឹក្សាក្នុងការគ្រប់គ្រងមុខងារជាជម្រើស

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដែលមិនមានបទពិសោធន៍ច្រើនក្នុងការគ្រប់គ្រងគម្រោង គួរជ្រើសរើសយកមុខងារជាជម្រើស ដែលងាយស្រួលក្នុងការគ្រប់គ្រង។ នៅក្នុងការពិនិត្យមើលសមត្ថភាពនៃការអនុវត្តមុខងារជាជម្រើស ក្រុមប្រឹក្សាគួរសហការជាមួយនឹងអ្នកពាក់ព័ន្ធផ្សេងទៀតដូចជា ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព

វិស័យឯកជន ឬសង្គមស៊ីវិលដែលមានបទពិសោធន៍ នៅក្នុងវិស័យដែលអាចផ្ដល់ជំនាញ ដែលរដ្ឋបាលមានការខ្វះខាតតាមរយៈការសហការជាដៃគូ ឬចុះកិច្ចសន្យាជាមួយគ្នា។ សកម្មភាពមុខងារជាជម្រើសមានទំហំខុសៗគ្នាអាស្រ័យលើសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ២.២.២. ការប៉ាន់ប្រមាណអំពីតម្រូវការធនធានរបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សា អាចជ្រើសរើសយកមុខងារជាជម្រើសមួយចំនួនដែលងាយស្រួលក្នុងការគ្រប់គ្រង និងបែងចែកថវិការបស់ខ្លួនទៅតាមមុខងារនេះ។ ប្រសិនបើក្រុមប្រឹក្សាជ្រើសរើសយកមុខងារដែលមានទំហំធំដែលត្រូវការថវិកាច្រើន នោះក្រុមប្រឹក្សាមិនអាចមានលទ្ធភាពចាត់ចែងបានព្រោះថវិការបស់ខ្លួនមានកម្រិត ដែលមិនអាចឆ្លើយតបតាមតម្រូវការជាច្រើនទៀតនៅមូលដ្ឋានបានឡើយ។ ម្យ៉ាងទៀតអាចបាត់បង់ឱកាសក្នុងការទទួលបានបទពិសោធន៍ពីការអនុវត្តមុខងារផ្សេងៗគ្នាជាច្រើន។ ក្រៅពីធនធានហិរញ្ញវត្ថុ ក្រុមប្រឹក្សាគួរពិចារណាទៅលើធនធានផ្សេងៗទៀត (ធនធានមនុស្ស ទ្រព្យសម្បត្តិ មធ្យោបាយនានា...) សម្រាប់អនុវត្តមុខងារជាជម្រើស។

### ២.២.៣. រយៈពេលនៃការអនុវត្តមុខងារជាជម្រើស

ក្រុមប្រឹក្សា គួរពិចារណាឱ្យបានល្អិតល្អន់នៅពេលជ្រើសរើសយកមុខងារជាជម្រើសដែលផ្ដល់សេវារយៈមួយសមស្រប ពីព្រោះមុខងារជាជម្រើស អាចប្រែប្រួលអាស្រ័យលើការយល់ឃើញរបស់ប្រជាពលរដ្ឋ ធនធាន និងសមត្ថភាពក្នុងការគ្រប់គ្រងរបស់ក្រុមប្រឹក្សា។ ដូចនេះ ក្រុមប្រឹក្សាគួរគិតអំពីរយៈពេលដែលបានគ្រោងទុក ក្នុងការផ្ដល់សេវា

ឱ្យសមស្របទៅនឹងសកម្មភាពជាអាទិភាព និងធនធានរបស់ខ្លួននៅពេលខាងមុខ។

ជាការប្រសើរបំផុត ក្រុមប្រឹក្សាគួរជ្រើសរើសយកមុខងារជាជម្រើសណាមួយដែលមានរយៈពេលអនុវត្ត មិនគួរលើសពីមួយឆ្នាំ ឬមិនគួរលើសពីអាណត្តិរបស់ក្រុមប្រឹក្សា។

ទោះបីយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាអាចផ្តួចផ្តើមក្នុងការជ្រើសរើសមុខងារជាជម្រើសមួយចំនួន ដែលត្រូវអនុវត្តក្នុងរយៈពេលវែងដោយមានមូលហេតុត្រឹមត្រូវ។

**ឧទាហរណ៍**៖ ក្រុមប្រឹក្សាបានបង្កើតបណ្ណាល័យសហគមន៍ ហើយក្រុមប្រឹក្សាមានហេតុផលសមស្របសម្រាប់ទុកជាមណ្ឌលធនធានឯកសារនៅក្នុងមូលដ្ឋាន ដូចនេះ ក្រុមប្រឹក្សាអាណត្តិថ្មីគួរបន្តគាំទ្រដំណើរការបណ្ណាល័យសហគមន៍នេះឱ្យដំណើរការសម្រាប់ឆ្នាំ និងអាណត្តិបន្តបន្ទាប់ទៀត។

### ២.៣. ការធ្វើសេចក្តីសម្រេចជាបឋមអំពីមុខងារជាជម្រើសដែលត្រូវជ្រើសរើស

អ្នកពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចជាបឋមអំពីមុខងារជាជម្រើសដែលត្រូវជ្រើសរើសនេះ រួមមាន៖

- ក្រុមប្រឹក្សា
- គណៈអភិបាល
- គណៈកម្មាធិការណាមួយរបស់ក្រុមប្រឹក្សា
- អង្គភាពពាក់ព័ន្ធណាមួយ
- មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង។

ដើម្បីឱ្យក្រុមប្រឹក្សាមានលទ្ធភាពធ្វើសេចក្ដីសម្រេច ដែលផ្អែកលើព័ត៌មានអំពីមុខងារជាជម្រើស ដែលនឹងត្រូវជ្រើសរើសយកមកអនុវត្ត គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ជំទប់ និងចៅសង្កាត់រង ត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនអំពីលទ្ធផលនៃការពិនិត្យមើលអំពីតម្រូវការអាទិភាពរបស់មូលដ្ឋាន និងការពិនិត្យមើលអំពីសមត្ថភាព និងធនធានរបស់ក្រុមប្រឹក្សាក្នុងការគ្រប់គ្រងមុខងារជាជម្រើស។ របាយការណ៍ជូនក្រុមប្រឹក្សាត្រូវបង្ហាញនូវជម្រើស និងអនុសាសន៍នានាអំពីមុខងារដែលគួរជ្រើសរើសដោយមានការបកស្រាយយ៉ាងច្បាស់អំពីគុណសម្បត្តិ និងគុណវិបត្តិនៃជម្រើសទាំងនោះ និងមូលហេតុនៃអនុសាសន៍នីមួយៗ។

បន្ទាប់មក ក្រុមប្រឹក្សាពិភាក្សា និងពិចារណាដើម្បីធ្វើសេចក្ដីសម្រេចអំពីការជ្រើសរើសមុខងារជាជម្រើស ដែលក្រុមប្រឹក្សាចង់យកមកអនុវត្ត។ ក្រុមប្រឹក្សាអាចសួរទៅគណៈអភិបាល ឬមេឃុំ ចៅសង្កាត់ ឬអ្នកជំនាញពាក់ព័ន្ធដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ (សូមមើលឯកសារបច្ចេកទេសស្ដីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា)។

ក្រុមប្រឹក្សាធ្វើសេចក្ដីសម្រេច និងណែនាំឱ្យនាយករដ្ឋបាលកត់ត្រាសេចក្ដីសម្រេចរបស់ខ្លួន ហើយសេចក្ដីសម្រេចនោះគួរបញ្ចូលផងដែរនូវជំហានបន្ទាប់ទៀត។

ក្នុងករណីមានចំណុចខ្វះខាត ក្រុមប្រឹក្សាអាចណែនាំឱ្យគណៈអភិបាល ឬគណៈកម្មាធិការណាមួយ ឬអង្គភាពពាក់ព័ន្ធណាមួយ មេឃុំ ចៅសង្កាត់ ធ្វើកិច្ចការណាមួយដូចខាងក្រោម ៖

- ស្រាវជ្រាវព័ត៌មានបន្ថែមពាក់ព័ន្ធនឹងមុខងារជាជម្រើស

ដែលបានស្នើឡើង និងធនធានដែលត្រូវការសម្រាប់អនុវត្តមុខងារនោះ

- ស្រាវជ្រាវព័ត៌មានទាក់ទងនឹងមុខងារជាជម្រើសណាមួយផ្សេងទៀតដែលមិនបានស្នើឡើងដោយគណៈអភិបាល គណៈកម្មាធិការ របស់ក្រុមប្រឹក្សា អង្គភាពពាក់ព័ន្ធណាមួយ ឬមេឃុំ ចៅសង្កាត់ ប៉ុន្តែក្រុមប្រឹក្សាមានការចាប់អារម្មណ៍ក្នុងការជ្រើសរើសយកមុខងារជាជម្រើសនោះមកអនុវត្ត
- ប្រមូលព័ត៌មានពីក្រុមប្រឹក្សាផ្សេងទៀតដែលធ្លាប់អនុវត្តមុខងារនោះ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានាប្រសិនបើចាំបាច់។

## ២.៤. ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នផ្សេងទៀតក្នុងការជ្រើសរើសមុខងារជាជម្រើស

អ្នកពាក់ព័ន្ធក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័នផ្សេងទៀតក្នុងការជ្រើសរើសមុខងារជាជម្រើសនេះ រួមមាន ៖

- គណៈអភិបាលរាជធានី ខេត្ត
- គណៈអភិបាលក្រុង ស្រុក ខណ្ឌ
- មេឃុំ ចៅសង្កាត់។

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ត្រូវជួយក្រុមប្រឹក្សារបស់ខ្លួនក្នុងការពិនិត្យមើល និងសិក្សាលើមុខងារជាជម្រើសដែលសម្រេចជ្រើសរើសជាបឋមដោយក្រុមប្រឹក្សា។ ចំពោះ

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលមិនអាចកំណត់បានថាមុខងារជាជម្រើសដែលបានសម្រេចជាបឋម ស្ថិតក្នុងប្រភេទណាមួយនៃមុខងារជាជម្រើស អាចស្នើសុំការគាំទ្រ និងសម្របសម្រួលពីអភិបាលរាជធានី ខេត្ត។ អភិបាលរាជធានី ខេត្ត អាចធ្វើប្រតិភូកម្មការទទួលខុសត្រូវនេះទៅឱ្យអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការកំណត់ថាមុខងារជាជម្រើសដែលបានសម្រេចជាបឋមនោះ ស្ថិតក្នុងប្រភេទណាមួយ។

ដើម្បីមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការពិនិត្យមើល និងសិក្សាលើមុខងារជាជម្រើសនោះ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ គួរស្វែងយល់អំពីប្រភេទនៃមុខងារជាជម្រើសដូចដែលបានបង្ហាញក្នុងនិយមន័យនៃផ្នែកទី១ខាងលើ។

បន្ទាប់មកអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំចៅសង្កាត់ គួរពិចារណាប្រើប្រាស់យន្តការដូចខាងក្រោមទៅតាមប្រភេទនៃមុខងារជាជម្រើសនីមួយៗ ៖

- ប្រសិនបើអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ពិនិត្យឃើញថា មុខងារដែលស្នើឡើងមិនស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល (ជាមុខងារជាជម្រើសប្រភេទទី១) នោះអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ត្រូវដាក់បញ្ចូលមុខងារជាជម្រើសទាំងនោះទៅក្នុងផែនការប្រចាំឆ្នាំ និងផែនការអភិវឌ្ឍន៍។

– ប្រសិនបើអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ពិនិត្យឃើញថា មុខងារដែលស្នើឡើងស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល (មុខងារជាជម្រើសប្រភេទទី២) អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវជូនដំណឹងទៅដល់ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ រួចអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវសម្របសម្រួល និងពិគ្រោះយោបល់ជាមួយ នឹងក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានា ក្នុងការជ្រើសរើសយកមុខងារជាជម្រើសនេះមកអនុវត្ត។

**ចំពោះមុខងារជាជម្រើសប្រភេទទី២** អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ត្រូវព្យាយាមធ្វើឱ្យមុខងារដែលក្រុមប្រឹក្សាចង់ជ្រើសរើសអាចដំណើរការទៅបានដោយជោគជ័យ។ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ នៅតែបន្តការគាំទ្រលើការអនុវត្ត មុខងារជាជម្រើសដែលជ្រើសរើសដោយក្រុមប្រឹក្សា ប្រសិនបើពុំមានរបាយការណ៍ចង្អុលបង្ហាញច្បាស់ថា ការជ្រើសរើសមុខងារជាជម្រើសរបស់ក្រុមប្រឹក្សា មិនផ្តល់ផលប្រយោជន៍ជូនដល់ប្រជាពលរដ្ឋ។

ក្នុងករណីមានរបាយការណ៍បង្ហាញថា មុខងារជាជម្រើសដែលក្រុមប្រឹក្សាជ្រើសរើស អាចមានផលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ អភិបាល មេឃុំ ចៅសង្កាត់ត្រូវផ្តល់យោបល់ជូនក្រុម

ប្រឹក្សា ដើម្បីសម្រេចបញ្ឈប់ការជ្រើសរើសមុខងារនេះ។

ក្នុងករណីមានការជំទាស់ពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលចំពោះមុខងារ ដែលក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិចង់ជ្រើសរើស ដោយមានសេចក្តីរាយការណ៍ ឬរបាយការណ៍ជាលាយលក្ខណ៍អក្សរមកអភិបាល និងមេឃុំ ចៅសង្កាត់ ដោយបញ្ជាក់អំពី ៖

- ការត្រួតគ្នាជាមួយនឹងផែនការរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានាពាក់ព័ន្ធ និងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត
- ភាពមានកម្រិតផ្នែកសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស។

ដូចនេះ អភិបាល និងមេឃុំ ចៅសង្កាត់ត្រូវរាយការណ៍ជូនក្រុមប្រឹក្សា អំពីការជំទាស់របស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលចំពោះមុខងារ ដែលក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិចង់ជ្រើសរើស។

ប្រសិនបើក្រុមប្រឹក្សា មិនឯកភាពចំពោះការជំទាស់របស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានា ក្រុមប្រឹក្សាត្រូវណែនាំ ឱ្យអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ដោយប្រើយន្តការអភិបាលរាជធានី ខេត្ត ស្នើសុំមក គ.ជ.អ.ប. ដើម្បី ជួយសម្របសម្រួល និងពិនិត្យសម្រេច។

<u>ឧទាហរណ៍៖</u> ក្រុមប្រឹក្សាស្រុក "ក" មានបំណងជ្រើសរើសមុខងារផ្តល់សេវាមត្តេយ្យសិក្សាសហគមន៍មកអនុវត្ត នៅពេលមន្ទីរអប់រំខេត្ត ពិនិត្យឃើញថាមុខងារនេះ កំពុងត្រូវបានអនុវត្ត ឬគ្រោង

អនុវត្តដោយមន្ទីរអប់រំខេត្ត ដូច្នេះមន្ទីរអប់រំខេត្តត្រូវជូនដំណឹងទៅអភិបាលស្រុក"ក" ដោយបញ្ជាក់ថា មុខងារដែលក្រុមប្រឹក្សាជ្រើសរើស នេះ មានភាពត្រួតគ្នាជាមួយនឹងផែនការរបស់មន្ទីរអប់រំខេត្ត។ បន្ទាប់ មក អភិបាលស្រុក ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាអំពីការជំទាស់របស់មន្ទីរអប់រំខេត្ត ដើម្បីឱ្យក្រុមប្រឹក្សាអាចពិចារណាឡើងវិញ។

## ២.៥. ការពិនិត្យមើលអំពីភាពត្រួតគ្នានៃមុខងារជាជម្រើស

អ្នកពាក់ព័ន្ធក្នុងការពិនិត្យមើលអំពីភាពត្រួតគ្នានៃមុខងារជាជម្រើស នេះរួមមាន៖

- ក្រុមប្រឹក្សា
- គណៈអភិបាល
- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា
- មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង

ក្រុមប្រឹក្សាណែនាំគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់របស់ខ្លួនពិនិត្យមើលថា តើមុខងារជាជម្រើសដែលខ្លួនចង់ជ្រើសរើសមានក្រុមប្រឹក្សាផ្សេងទៀត (ដែលមានដែនដីត្រួតគ្នា) នៅក្នុងមូលដ្ឋានបាន ឬមានបំណងជ្រើសរើសយកមុខងារជាជម្រើសដូចគ្នាមកអនុវត្តដែរឬទេ។ ក្នុងការពិនិត្យមើលអំពីការត្រួតស៊ីគ្នានៃមុខងារជាជម្រើសនេះគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ អាចរៀបចំការពិគ្រោះយោបល់គ្នាទៅវិញទៅមកជាមួយក្រុមប្រឹក្សាផ្សេងទៀត ដោយប្រើយន្តការគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សា ដោយពិចារណាករណីដូចខាងក្រោម ៖

- ក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នាសម្រេចជ្រើសរើស

យកមុខងារជាជម្រើសមួយ ឬច្រើនដូចគ្នា ក្រុមប្រឹក្សាទាំងនេះគួរជួបប្រជុំ និងពិភាក្សាដើម្បីស្វែងរកកិច្ចសហប្រតិបត្តិការជាមួយគ្នាដោយប្រើយន្តការ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ខ្លួន ដោយបង្កើតជាកិច្ចព្រមព្រៀងសហប្រតិបត្តិការរួមគ្នាសម្រាប់ជាមូលដ្ឋានក្នុងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានីមួយៗ។

- ចំពោះក្រុមប្រឹក្សាប្រភេទផ្សេងគ្នា (ដូចជា ក្រុមប្រឹក្សាខេត្ត និងក្រុង ឬខេត្ត និងស្រុក ឬស្រុក និងឃុំ ឬក្រុង និងសង្កាត់) ជ្រើសរើសយកមុខងារដូចគ្នាមកអនុវត្ត ក្រុមប្រឹក្សាទាំងនេះ ត្រូវធានាឱ្យមានការសម្របសម្រួលគ្នាដោយប្រើយន្តការគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សារៀងៗខ្លួន។ ការសម្របសម្រួលគួរធ្វើយ៉ាងណាជួយដល់ក្រុមប្រឹក្សាទាំងនោះ ដើម្បីអាចអនុវត្តមុខងារដោយរលូន និងសន្សំសំចៃថវិកា។

ប្រសិនបើក្រុមប្រឹក្សាណាមួយយល់ឃើញថា ការអនុវត្តមុខងារជាជម្រើសដូចគ្នាមិនទទួលបានជោគជ័យ ក្រុមប្រឹក្សានោះអាចបញ្ឈប់ការអនុវត្តមុខងារជាជម្រើសនោះបាន ហើយក្រុមប្រឹក្សាផ្សេងទៀតដែលអាចអនុវត្តបានដោយជោគជ័យគួរបន្តអនុវត្តមុខងារនោះ។

ប្រសិនបើក្រុមប្រឹក្សាថ្នាក់ខុសៗគ្នា មានសមត្ថភាពប្រហាក់ប្រហែលគ្នា ហើយចង់អនុវត្តមុខងារដូចគ្នាក្នុងទីកន្លែងតែមួយ ក្រុមប្រឹក្សាដែលនៅកៀកប្រជាពលរដ្ឋបំផុត គួរទទួលបានអាទិភាពក្នុងការអនុវត្តមុខងារនេះ។

**ឧទាហរណ៍** ៖ ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាសង្កាត់មួយនៅក្នុងក្រុងនោះ ចង់ជ្រើសរើសមុខងារជាជម្រើសស្តីពីការរៀបចំប្រព័ន្ធគ្រប់គ្រងកាកសំណល់នៅក្នុងសង្កាត់។ តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាសង្កាត់ ប្រសិនបើក្រុមប្រឹក្សាទាំងពីរយល់ឃើញថាក្រុមប្រឹក្សាសង្កាត់ មានសមត្ថភាពប្រហាក់ប្រហែលក្រុមប្រឹក្សាក្រុងដែរក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងកាកសំណល់ ដូច្នេះក្រុមប្រឹក្សាក្រុង គួរសម្រេចប្រគល់មុខងារនេះទៅឱ្យក្រុមប្រឹក្សាសង្កាត់ជាអ្នកអនុវត្ត ព្រោះសង្កាត់នៅកៀកប្រជាពលរដ្ឋជាង។

ប្រសិនបើមិនមានការឯកភាពគ្នា អំពីមុខងារជាជម្រើសរវាងក្រុមប្រឹក្សានីមួយៗ ក្រុមប្រឹក្សាណែនាំឱ្យអភិបាលរាជធានី ខេត្ត ធ្វើការសម្របសម្រួល ដើម្បីប្រគល់មុខងារនេះទៅឱ្យក្រុមប្រឹក្សាសង្កាត់ជាអ្នកអនុវត្ត។

## ២.៦. ការធ្វើសេចក្តីសម្រេចចុងក្រោយអំពីការជ្រើសរើសមុខងារជាជម្រើស

អ្នកពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយអំពីការជ្រើសរើសមុខងារជាជម្រើស រួមមាន៖

- ក្រុមប្រឹក្សា
- គណៈអភិបាល
- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា
- អង្គភាពពាក់ព័ន្ធនានា
- មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង

គណៈអភិបាល ឬមេឃុំ ចៅសង្កាត់ ត្រូវរាយការណ៍អំពីលទ្ធផល និងអនុសាសន៍នានានៃកិច្ចការទី៨ស្តីពីការសម្របសម្រួលជាមួយ

ក្រសួងស្ថាប័នផ្សេងទៀត និងកិច្ចការទី៥ ស្តីពីការពិនិត្យមើលអំពីការត្រួតគ្នានៃមុខងារជាជម្រើសជូនក្រុមប្រឹក្សារបស់ខ្លួន ដើម្បីធ្វើសេចក្តីសម្រេចចុងក្រោយ។ របាយការណ៍គួរបញ្ជាក់អំពីជម្រើស និងអនុសាសន៍ទាំងឡាយណា ដែលមានការកែសម្រួលនៅផ្នែកណាមួយនៃកិច្ចការទី២ ស្តីពីការពិនិត្យមើលអំពីសមត្ថភាព និងធនធានរបស់ក្រុមប្រឹក្សាក្នុងការគ្រប់គ្រងមុខងារជាជម្រើសដែលគណៈអភិបាល ឬមេឃុំ ចៅសង្កាត់បានដាក់ជូនក្រុមប្រឹក្សា។

បន្ទាប់មក ក្រុមប្រឹក្សាពិភាក្សា និងអនុម័តលើសេចក្តីសម្រេចចុងក្រោយអំពីមុខងារជាជម្រើសណា ដែលក្រុមប្រឹក្សានឹងត្រូវជ្រើសរើសយកមកអនុវត្ត។

# ផ្នែកទី៣
# ការរៀបចំផែនការសកម្មភាព និងថវិកា សម្រាប់អនុវត្តមុខងារជាជម្រើស

ផ្នែកទី៣ នឹងជួយក្រុមប្រឹក្សាឱ្យបានយល់ដឹងអំពីការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តមុខងារជាជម្រើស។ ក្រុមប្រឹក្សាត្រូវដាក់បញ្ចូលមុខងារជាជម្រើសទៅក្នុងផែនការសកម្មភាព និង ថវិកាសម្រាប់អនុវត្តមុខងារជាជម្រើសក្នុងដំណើរការកសាងកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់។

ដូច្នេះក្រុមប្រឹក្សាត្រូវយោងទៅលើលិខិតបទដ្ឋាន និងគោលការណ៍ណែនាំជាធរមានអំពីការរៀបចំផែនការសកម្មភាព និងថវិកា ដើម្បីរៀបចំផែនការសកម្មភាព និងថវិកាក្នុងការអនុវត្តមុខងារជាជម្រើស។ អ្នកពាក់ព័ន្ធក្នុងកិច្ចការនេះរួមមាន ៖

- ក្រុមប្រឹក្សា
- គណៈអភិបាល
- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា
- អង្គភាពពាក់ព័ន្ធនានា
- មេឃុំចៅសង្កាត់ជំទប់ ចៅសង្កាត់រង

ក្នុងនាមក្រុមប្រឹក្សា គណៈអភិបាល គណៈកម្មាធិការរបស់ក្រុមប្រឹក្សា អង្គភាពពាក់ព័ន្ធនានា មេឃុំ ចៅសង្កាត់ ត្រូវបំពេញកិច្ចការមួយចំនួនដូចខាងក្រោម ៖

១. ការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តមុខងារជាជម្រើស

២. ការរៀបចំគម្រោងចំណាយប៉ាន់ស្មានសម្រាប់ការអនុវត្តមុខងារជាជម្រើស

៣. ការបញ្ចូលផែនការសកម្មភាព និងថវិការបស់មុខងារជាជម្រើសទាំងនោះទៅក្នុងកម្មវិធីវិនិយោគ

៤. ការកែសម្រួលថវិកាប្រចាំឆ្នាំ។

## ៣.១. ការរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តមុខងារជាជម្រើស

ការរៀបចំផែនការសកម្មភាពមុខងារជាជម្រើស គឺជាកិច្ចការមួយដ៏សំខាន់ ដែលត្រូវធ្វើឡើងជាទៀងទាត់ និងគួរដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់។ ដូច្នេះនីតិវិធីនៃការកសាងផែនការមុខងារជាជម្រើស មានលក្ខណៈដូចគ្នានឹងការកសាងផែនការសកម្មភាព/មុខងារផ្សេងទៀតរបស់ក្រុមប្រឹក្សាដែរ។

ក្នុងការរៀបចំផែនការសកម្មភាព និងថវិការបស់ខ្លួន ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗពិចារណាលើសកម្មភាព មួយចំនួនដូចខាងក្រោម ៖

- នៅពេលចាប់ផ្តើមនៃអាណត្តិរបស់ខ្លួន ក្រុមប្រឹក្សានីមួយៗ ត្រូវអនុម័តផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ដែលបញ្ចូលមុខងារជាជម្រើស

ដែលក្រុមប្រឹក្សាមានបំណងជ្រើសរើសយកមកអនុវត្ត។

- ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក៏អនុម័តផងដែរ លើក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដែលព្យាករណ៍ប្រភេទថវិកាចំណាយ ក្នុងរយៈពេលបីឆ្នាំ (រហូតប្រាំឆ្នាំ)ដោយរួមបញ្ចូលទាំងមុខងារជាជម្រើស។
- ក្រុមប្រឹក្សា ធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំនូវកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ខ្លួន ដោយរួមបញ្ចូលទាំងមុខងារជាជម្រើសថ្មី ឬមុខងារជាជម្រើសដែលបានកែសម្រួល។
- ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចធ្វើការកែសម្រួលនូវកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ខ្លួន ដើម្បីដាក់បញ្ចូលនូវមុខងារជាជម្រើសថ្មីនៅពេលណាមួយ ដោយផ្អែកទៅលើសំណូមពរ និងតម្រូវការជាក់ស្តែងរបស់មូលដ្ឋាន។
- ក្រុមប្រឹក្សាត្រូវសម្របសម្រួលជាមួយក្រុមប្រឹក្សាប្រភេទដូចគ្នា និងក្រុមប្រឹក្សាប្រភេទផ្សេងគ្នាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានានៅក្នុងអំឡុងពេលនៃដំណើរ ការកសាងកម្មវិធីវិនិយោគប្រចាំឆ្នាំ ក្នុងការដាក់បញ្ចូលនូវមុខងារជាជម្រើស។

<u>កំណត់សម្គាល់</u>៖

- សម្រាប់មុខងារជាជម្រើស ដែលស្ថិតនៅក្នុងប្រភេទទី២ ក្រុមប្រឹក្សាគួរត្រៀមលក្ខណៈទុកជាមុននៅក្នុងអំឡុងពេលនៃដំណើរការកសាងផែនការដើម្បីធានាឱ្យមានការសម្របសម្រួលដោយរលូន។ ការសម្របសម្រួលជាមួយ

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល គួរធ្វើឡើងចាប់តាំងពីពេលដំបូងដែលអាចជួយកាត់បន្ថយការកែតម្រូវផែនការរបស់ក្រុមប្រឹក្សានៅពេលដាក់បញ្ចូលមុខងារជាជម្រើសក្នុងកម្មវិធីវិនិយោគ។

**ឧទាហរណ៍៖**

- ប្រសិនបើក្រុមប្រឹក្សាជ្រើសរើសយកមុខងារប្រមូល និងការគ្រប់គ្រងសំរាម ក្រុមប្រឹក្សាត្រូវធានាថាកុំឱ្យរំលោភបំពានលើបទប្បញ្ញត្តិនានារបស់រាជរដ្ឋាភិបាល ទាក់ទងនឹងការគ្រប់គ្រងសំរាម ហើយក្រុមប្រឹក្សាអាចជួបជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានា ដូចជាការិយាល័យ ឬមន្ទីរបរិស្ថាន។
- ប្រសិនបើក្រុមប្រឹក្សាមានបំណងអនុវត្តមុខងារដែលពាក់ព័ន្ធនឹងសុខភាព ក្រុមប្រឹក្សាគួរជួបជាមួយមន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានាដូចជា មណ្ឌលសុខភាព ការិយាល័យស្រុកប្រតិបត្តិ ឬមន្ទីរសុខាភិបាលខេត្ត និងអង្គការមិន មែនរដ្ឋាភិបាល ដែលអនុវត្តសកម្មភាពទាក់ទងនឹងសុខភាព។

## ៣.២. ការរៀបចំគម្រោងចំណាយប៉ាន់ស្មានសម្រាប់ការអនុវត្តមុខងារជាជម្រើស

បណ្ណាល័យ

មុនពេលរៀបចំគម្រោងចំណាយប៉ាន់ស្មាន សម្រាប់ការអនុវត្តមុខងារជាជម្រើស ក្រុមប្រឹក្សាគួរពិចារណាថា តើមុខងារជាជម្រើសដែលត្រូវអនុវត្តនោះត្រូវការថវិកា ឬមិនត្រូវការ។

មុខងារជាជម្រើសទាំងឡាយដែលត្រូវការថវិកា ក្រុមប្រឹក្សាគួរធ្វើការប៉ាន់ស្មានថវិកា និងកំណត់ប្រភពធនធានសម្រាប់រ៉ាប់រងលើការអនុវត្តមុខងារទាំងនោះ។ ក្នុងការរៀបចំគម្រោងចំណាយប៉ាន់ស្មានសម្រាប់អនុវត្តមុខងារជាជម្រើស ក្រុមប្រឹក្សាត្រូវអនុវត្តតាមលិខិតបទដ្ឋាន និងសេចក្តីណែនាំស្តីពីការរៀបចំគម្រោងថវិកា ដែលមានជាធរមាន។

ក្នុងការរៀបចំគម្រោងចំណាយប៉ាន់ស្មាន សម្រាប់ការអនុវត្តមុខងារជាជម្រើស ក្រុមប្រឹក្សាអាចកំណត់ប្រភពធនធាន ដែលបានមកពីមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ ប្រភពពីរាជរដ្ឋាភិបាល ប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រភពបដិភាគពីដៃគូអភិវឌ្ឍន៍ និងប្រភពផ្សេងៗទៀត។

### ៣.២.១. ប្រភពមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ

ក្រុមប្រឹក្សាសម្រេចអំពីរបៀបចាត់ចែង និងគ្រប់គ្រងមូលនិធិសម្រាប់មុខងារជាជម្រើសដែលមានបំណងយកមកអនុវត្ត។ ជាការសំខាន់ណាស់ ដែលក្រុមប្រឹក្សាប្រើប្រាស់មូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌរបស់ខ្លួនជាមួយមូលនិធិបន្ថែម ដែលក្រុមប្រឹក្សាទទួលបានមកពីប្រភពខាងក្នុង និងពីប្រភពខាងក្រៅដែនសមត្ថកិច្ចរបស់ខ្លួន ឬចំណូលពីប្រភពផ្សេងទៀត ដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តអនុញ្ញាត។

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬមេឃុំ ចៅសង្កាត់ អង្គភាពពាក់ព័ន្ធនានា និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាត្រូវផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាអំពីរបៀបចាត់ចែង និងគ្រប់គ្រងធនធានមូលនិធិ សម្រាប់ការអនុវត្តមុខងារជាជម្រើសឱ្យបានល្អ។

### ៣.២.២. ប្រភពពីរាជរដ្ឋាភិបាល

មុខងារជាជម្រើសអាចប្រើប្រាស់មូលនិធិមួយផ្នែកនៃមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌដែលក្រុមប្រឹក្សាទទួលពីថ្នាក់ជាតិ។

### ៣.២.៣. ប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

នៅពេលខាងមុខអាចនឹងមានបទបញ្ញត្តិនានា ដែលកំណត់អំពីប្រភេទចំណូល ដែលត្រូវប្រមូលនៅមូលដ្ឋានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមានចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ក្រុមប្រឹក្សាអាចសម្រេចប្រើប្រាស់ចំណូលទាំងនេះសម្រាប់អនុវត្តមុខងារជាជម្រើសរបស់ខ្លួន។

### ៣.២.៤. ប្រភពបដិភាគពីដៃគូអភិវឌ្ឍន៍

ដៃគូអភិវឌ្ឍន៍នានាអាចផ្តល់ថវិកា និងឬជំនួយបច្ចេកទេសទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិដោយផ្ទាល់។ សម្រាប់ការផ្តល់ថវិកាពីដៃគូអភិវឌ្ឍន៍អាចផ្តល់តាមរយៈប្រព័ន្ធថវិកាជាតិ ឬតាមរយៈធនាគារពាណិជ្ជណាមួយ។ សម្រាប់នីតិវិធី និងបែបបទដើម្បីអនុវត្ត គ្រប់គ្រងចាត់ចែងថវិកាទាំងនោះ អាចមានចែងក្នុងអនុសារណៈនៃការយោគយល់រវាងដៃគូអភិវឌ្ឍន៍ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៣.២.៥. ប្រភពពីវិស័យឯកជន ឬសហគមន៍ឬសង្គមស៊ីវិលនានា

ក្រុមប្រឹក្សាអាចប្រើប្រាស់ប្រភពថវិកាបានមកពីវិស័យឯកជន ឬសហគមន៍ ឬសង្គមស៊ីវិលនានាសម្រាប់ការអនុវត្តមុខងារជាជម្រើសដែលបានជ្រើសរើសរបស់ខ្លួន។ សម្រាប់នីតិវិធី និងបែបបទដើម្បីអនុវត្តគ្រប់គ្រង និងចាត់ចែងថវិកាទាំងនោះអាចមានចែងក្នុងអនុសារណៈនៃការយោគយល់រវាងវិស័យឯកជន ឬសហគមន៍ ឬសង្គមស៊ីវិលនានា

ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៣.២.៦. គម្រោងនានារបស់ដៃគូអភិវឌ្ឍន៍

ក្រុមប្រឹក្សាមានសិទ្ធិចូលរួមធ្វើសេចក្ដីសម្រេចចិត្តក្នុងការដាក់បញ្ចូលគម្រោងសកម្មភាពនានារបស់ដៃគូអភិវឌ្ឍន៍ ដែលនឹងអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សា។ ក្នុងករណីបែបនេះ ដៃគូអភិវឌ្ឍន៍ផ្តល់ហិរញ្ញប្បទានដល់សកម្មភាពគម្រោងរបស់ខ្លួនផ្ទាល់ ហើយមូលនិធិសម្រាប់អនុវត្តមុខងារជាជម្រើសនេះមិនផ្តល់តាមរយៈថវិការបស់ក្រុមប្រឹក្សាទេ។

## ៣.៣. ការបញ្ចូលផែនការសកម្មភាព និងថវិកានៅក្នុងកម្មវិធីវិនិយោគ

ក្រុមប្រឹក្សាត្រូវបញ្ចូលផែនការសកម្មភាព និងថវិកានៃមុខងារជាជម្រើសទៅក្នុងកម្មវិធីវិនិយោគប្រចាំឆ្នាំរំកិលរបស់ក្រុមប្រឹក្សានីមួយៗ ដោយស្របទៅតាមនីតិវិធីនៃការរៀបចំកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ខ្លួនបន្ទាប់ពីក្រុមប្រឹក្សាបានរៀបចំផែនការសកម្មភាព និងថវិកានៃការអនុវត្តមុខងារជាជម្រើសដែលខ្លួនបានជ្រើសរើសរួចហើយ។

## ៣.៤. ការរៀបចំគម្រោងថវិកា និងការកែសម្រួលថវិកាប្រចាំឆ្នាំ

ក្រុមប្រឹក្សា ត្រូវដាក់បញ្ចូលនៅក្នុងគម្រោងថវិការបស់ខ្លួននូវចំណូល និងចំណាយទាំងអស់ដោយមិនគិតអំពីប្រភព ព្រមទាំងបញ្ចូលគម្រោង ថវិកាសម្រាប់អនុវត្តមុខងារជាជម្រើសដែលខ្លួនបានជ្រើសរើសផងដែរ នៅតាមរដ្ឋបាលនីមួយៗ រួមមាន ៖

### ៣.៤.១. គម្រោង និងការកែសម្រួលថវិការបស់ក្រុមប្រឹក្សារាជធានី ខេត្ត

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្តត្រូវរៀបចំថវិការបស់ខ្លួន ដើម្បីអនុវត្តមុខងារជាជម្រើសដែលក្រុមប្រឹក្សាបានជ្រើសរើស ដោយប្រើប្រាស់ថវិការបស់រាជធានី ខេត្ត និងប្រភពថវិកាផ្សេងៗទៀត។

ក្នុងការរៀបចំ និងប្រើប្រាស់ថវិកា ក្រុមប្រឹក្សាត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន ក្នុងការធ្វើកែសម្រួលថវិការបស់ខ្លួន។

### ៣.៤.២. គម្រោង និងការកែសម្រួលថវិកាក្រុមប្រឹក្សាខណ្ឌ សង្កាត់

ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់ក្នុងរាជធានី ត្រូវរៀបចំថវិការបស់ខ្លួន ដើម្បីអនុវត្តមុខងារជាជម្រើសដែលក្រុមប្រឹក្សាបានជ្រើសរើសដោយប្រើប្រាស់ថវិការបស់រាជធានី និងប្រភពថវិកាផ្សេងៗទៀត។

ក្នុងការរៀបចំ និងប្រើប្រាស់ថវិកា ក្រុមប្រឹក្សាត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន ក្នុងការធ្វើកែសម្រួលថវិការបស់ខ្លួន។

### ៣.៤.៣. គម្រោង និងការកែសម្រួលថវិការបស់ក្រុមប្រឹក្សាក្រុង ស្រុក

ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុកទាំងអស់មានមូលនិធិផ្ទាល់ខ្លួនសម្រាប់បម្រើឱ្យការងាររដ្ឋបាល និងកិច្ចការអភិវឌ្ឍន៍មូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាអាចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការចាត់ចែង និងគ្រប់គ្រងមូលនិធិក្រុង ស្រុក ដើម្បីអនុវត្តមុខងារជាជម្រើស។

ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន គឺជាប្រភេទមូលនិធិក្រុង ស្រុក សម្រាប់រ៉ាប់រងការចំណាយមូលធន និងឬការចំណាយចរន្តទាក់ទងនឹងមុខងារផ្តល់សេវា។ ដូច្នេះធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋានអាចអនុវត្តមុខងារជាជម្រើស។

ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក អាចធ្វើកែសម្រួលថវិការបស់ខ្លួននៅក្នុងអំឡុងពេលនៃឆ្នាំសារពើពន្ធ ប្រសិនបើលក្ខខណ្ឌសេដ្ឋកិច្ច ឬចំណូលមានការប្រែប្រួល។ ប្រការនេះ អនុញ្ញាតឱ្យមានភាពបត់បែនបានចំពោះក្រុមប្រឹក្សាណាដែលទទួលព័ត៌មានមិនទាន់ពេលអំពីចំណូលដែលមាន ឬសកម្មភាពដែលចង់អនុវត្តអាចស្ថិតនៅក្នុងមុខងារជាជម្រើស។

ក្នុងការរៀបចំ និងប្រើប្រាស់ថវិកា ក្រុមប្រឹក្សាត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន ក្នុងការធ្វើកែសម្រួលថវិការបស់ខ្លួន។

### ៣.៤.៤. គម្រោង និងការកែសម្រួលថវិកាក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ មានមូលនិធិផ្ទាល់ខ្លួនសម្រាប់បម្រើឱ្យការងាររដ្ឋបាល និងកិច្ចការអភិវឌ្ឍន៍មូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ អាចប្រើប្រាស់ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋានសម្រាប់រ៉ាប់រងលើចំណាយមូលធន និងឬចំណាយចរន្តដែលបម្រើឱ្យគោលបំណងនៃការអភិវឌ្ឍមូលដ្ឋាន។ ដូច្នេះ ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន អាចប្រើប្រាស់សម្រាប់ការអនុវត្តមុខងារជាជម្រើស។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើកែសម្រួលថវិការបស់ខ្លួននៅក្នុងអំឡុងពេលនៃឆ្នាំសារពើពន្ធ ប្រសិនបើស្ថានភាពសេដ្ឋកិច្ច ឬចំណូលថវិការបស់រដ្ឋបាលមានការប្រែប្រួល។ ប្រការនេះ អនុញ្ញាតឱ្យមានភាពបត់បែនបានចំពោះក្រុមប្រឹក្សាណា ដែលទទួលព័ត៌មានមិនទាន់ពេលអំពីចំណូលដែលមាន ឬសកម្មភាពដែលចង់អនុវត្តអាចស្ថិតនៅក្នុងមុខងារជាជម្រើស។

ក្នុងការរៀបចំ និងប្រើប្រាស់ថវិកា ក្រុមប្រឹក្សាត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន ក្នុងការធ្វើកែសម្រួលថវិការបស់ខ្លួន។

# ផ្នែកទី ៤

# ការអនុវត្តមុខងារជាជម្រើស

ផ្នែកទី៤ "ការអនុវត្តមុខងារជាជម្រើស" ផ្តល់ដល់ក្រុមប្រឹក្សានូវជម្រើសនានា អំពីរបៀបអនុវត្តមុខងារជាជម្រើស និងអំពីរបៀបដែលក្រុមប្រឹក្សាទទួលបានព័ត៌មានជាប្រចាំ។

អ្នកពាក់ព័ន្ធសំខាន់ៗមួយចំនួន ដែលក្រុមប្រឹក្សាគួរពិចារណាក្នុងការអនុវត្តមុខងារជាជម្រើស៖

- ក្រុមប្រឹក្សា
- គណៈអភិបាល
- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា
- អង្គភាពពាក់ព័ន្ធនានា
- មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង
- សង្គមស៊ីវិលនិងផ្នែកឯកជន។

ដើម្បីអនុវត្តមុខងារជាជម្រើស ក្រុមប្រឹក្សាត្រូវអនុវត្តកិច្ចការមួយចំនួនដូចខាងក្រោម ៖

១. កំណត់អ្នកពាក់ព័ន្ធដែលនឹងអនុវត្តមុខងារជាជម្រើស

២. ការធ្វើលទ្ធកម្មសម្រាប់អនុវត្តមុខងារជាជម្រើស។

## ៤.១. កំណត់អ្នកពាក់ព័ន្ធដែលនឹងអនុវត្តមុខងារជាជម្រើស

ក្នុងការកំណត់អ្នកពាក់ព័ន្ធដែលអាចអនុវត្តមុខងារជាជម្រើស ក្រុមប្រឹក្សាអាចពិចារណាជម្រើសដូចខាងក្រោម ៖

- ប្រើប្រាស់បុគ្គលិករបស់ខ្លួននិងឬ

បណ្ណាល័យ
គ.ជ.អ.ប

– ធ្វើកិច្ចសហប្រតិបត្តិការ ឬចុះកិច្ចសន្យាជាមួយក្រុមប្រឹក្សាផ្សេងទៀត ឬផ្នែកឯកជន ឬសង្គមស៊ីវិល។

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ត្រូវសិក្សាអំពីគុណសម្បត្តិ និងគុណវិបត្តិនៃជម្រើសទាំងពីរខាងលើដោយបញ្ជាក់ពីហេតុផល មុននឹងលើកយោបល់ជូនក្រុមប្រឹក្សាពិនិត្យនិងធ្វើសេចក្តីសម្រេច។

ក្រុមប្រឹក្សាធ្វើសេចក្តីសម្រេចអំពីអ្នកពាក់ព័ន្ធដែលនឹងអនុវត្តមុខងារជាជម្រើសក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។

### ៤.១.១. ជម្រើសទី១ ៖ ការអនុវត្តមុខងារជាជម្រើសដោយបុគ្គលិករបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សា អាចសម្រេចប្រើប្រាស់បុគ្គលិករបស់ខ្លួនដែលមានស្រាប់ឱ្យទទួលរ៉ាប់រងអនុវត្តមុខងារជាជម្រើសណាមួយ។

ប្រសិនបើបុគ្គលិករបស់ក្រុមប្រឹក្សាមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តមុខងារជាជម្រើសទាំងនោះបាន ក្រុមប្រឹក្សាត្រូវជួលបុគ្គលិកបន្ថែមទៀតដើម្បីអនុវត្តមុខងារនេះ។ ការជួលបុគ្គលិកក៏ត្រូវគិតផងដែរអំពីរយៈពេលនៃការអនុវត្តមុខងារជាជម្រើស ថាតើមុខងារទាំងនោះជាសកម្មភាពបណ្តោះអាសន្ន ឬស្ថិតនៅក្នុងដំណាក់កាលសាកល្បងនៅឡើយ។ ក្រុមប្រឹក្សាត្រូវគិតគូរពិចារណាដោយប្រុងប្រយ័ត្ន ថាតើជាការសមស្របឬទេក្នុងការជួលបុគ្គលិកថ្មី។

### ៤.១.២. ជម្រើសទី២ ៖ ការអនុវត្តមុខងារជាជម្រើសដោយសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធ

ការអនុវត្តមុខងារជាជម្រើស ក្រុមប្រឹក្សាអាចធ្វើកិច្ចសហប្រតិបត្តិ

ការ ឬចុះកិច្ចសន្យាជាមួយអ្នកពាក់ព័ន្ធនានា ដូចជា ៖

- ក្រុមប្រឹក្សាអាចធ្វើកិច្ចសហប្រតិបត្តិការ ឬចុះកិច្ចសន្យាជាមួយក្រុមប្រឹក្សាផ្សេងទៀត ឬមន្ទីរ អង្គភាពជំនាញនានា
- ក្រុមប្រឹក្សាអាចចុះកិច្ចសន្យាជាមួយផ្នែកឯកជន សង្គមស៊ីវិលដើម្បីអនុវត្តមុខងារជាជម្រើស។

ក្រុមប្រឹក្សាត្រូវតែអនុវត្ត តាមច្បាប់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាធរមាន។ សកម្មភាពនៃការអនុវត្តមុខងារជាជម្រើសនីមួយៗ គួរមានកិច្ចសន្យាដាច់ដោយឡែកពីគ្នា។ គណៈកម្មាធិការលទ្ធកម្មនឹងត្រូវផ្តល់យោបល់ដល់គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬមេឃុំ ចៅសង្កាត់ពាក់ព័ន្ធនឹងដំណើរការលទ្ធកម្ម បន្ទាប់មកដាក់ជូនក្រុមប្រឹក្សាដើម្បីពិនិត្យ និងសម្រេច។

មុនពេលចុះកិច្ចសន្យា ពាក់ព័ន្ធទៅនឹងការអនុវត្តមុខងារនេះ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬ មេឃុំ ចៅសង្កាត់ត្រូវសម្របសម្រួលជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធនានា ដើម្បីធានាអំពីបទដ្ឋានបច្ចេកទេសផលប៉ះពាល់បរិស្ថាន និងស្របតាមបទដ្ឋានសុវត្ថិភាពផ្សេងៗ។

ក្រុមប្រឹក្សាអាចសម្រេចចិត្តរួមគ្នាក្នុងការជួល និងចែករំលែកបុគ្គលិក ឬឱ្យអ្នកផ្តល់សេវាផ្សេងៗទៀតរួមគ្នាក្នុងការសហការអនុវត្តមុខងារជាជម្រើស។ ក្នុងករណីនេះ ការជួល ឬការចុះកិច្ចសន្យា គួរត្រូវរៀបចំឡើងដោយក្រុមប្រឹក្សាមួយ ចំណែកក្រុមប្រឹក្សាមួយទៀតត្រូវផ្តល់ការរួមចំណែកផ្នែកហិរញ្ញវត្ថុ។

**កំណត់សម្គាល់** ៖ កិច្ចព្រមព្រៀងនៃកិច្ចសហប្រតិបត្តិការមានភាពចាំបាច់ណាស់ក្នុងការធានាឱ្យភាគីនីមួយៗយល់ដឹងច្បាស់អំពីតួនាទីរបស់ខ្លួន ជាពិសេសអំពីការគ្រប់គ្រង និងគណនេយ្យភាពរបស់អ្នកផ្តល់សេវាដែលបានជួលឱ្យមកបម្រើការងារ។

## ៤.២. ការធ្វើលទ្ធកម្មសម្រាប់ការអនុវត្តមុខងារជាជម្រើស

គណៈកម្មាធិការលទ្ធកម្មរបស់ក្រុមប្រឹក្សា ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាទាក់ទងនឹងរបៀបធ្វើលទ្ធកម្មទំនិញ សម្ភារៈ និងសេវាទាក់ទងនឹងការអនុវត្តមុខងារជាជម្រើស។ ក្រុមប្រឹក្សាធ្វើសេចក្តីសម្រេចចុងក្រោយអំពីលទ្ធកម្មនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។

ក្រុមប្រឹក្សាអាចពិចារណាលើប្រភេទលទ្ធកម្មដូចខាងក្រោមក្នុងការអនុវត្តមុខងារជាជម្រើស៖

- **កិច្ចសន្យាសំណង់ និងជួសជុល**៖ នេះជាកិច្ចសន្យារវាងក្រុមប្រឹក្សា និងអ្នកម៉ៅការឯកជន ដើម្បីធ្វើការសាងសង់ ឬការងារថែទាំ។ ឧទាហរណ៍ ៖ ការជួសជុលដំបូលសាលារៀន។
- **កិច្ចសន្យាសេវា**៖គឺជាកិច្ចសន្យារវាងក្រុមប្រឹក្សា និងអ្នកផ្តល់សេវាដែលនឹងអនុវត្តសេវាជាក់លាក់មួយ។ ឧទាហរណ៍៖ ថ្នាក់អក្ខរកម្មមនុស្សពេញវ័យ ការបណ្តុះបណ្តាលកសិករ។
- **ការបញ្ជាទិញ**៖ ក្រុមប្រឹក្សាប្រើប្រាស់ការបញ្ជាទិញ ដើម្បីទិញឧបករណ៍ គ្រឿងសង្ហារឹម ឬទំនិញ សម្ភារៈផ្សេងៗ

ទៀត។ <u>**ឧទាហរណ៍**</u> ៖ ម៉ាស៊ីនបូមទឹក ស្បៀងអាហារសម្រាប់កុមារ ឬអ្នកជំងឺ។

- **កិច្ចសន្យាសេវាទីប្រឹក្សា** ៖ នេះជាកិច្ចសន្យារវាងក្រុមប្រឹក្សា និងក្រុមហ៊ុនទីប្រឹក្សា ឬទីប្រឹក្សាឯកត្តជនដែលផ្តល់សេវាជំនាញការពាក់ព័ន្ធគម្រោងណាមួយ ឬសម្រាប់អភិវឌ្ឍស្ថាប័ន ឬ បង្កើនសមត្ថភាព។

**កំណត់សម្គាល់** ៖ គ្រប់កិច្ចការលទ្ធកម្មទាំងអស់ត្រូវអនុវត្តទៅតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានជាធរមាន។

# ផ្នែកទី៥

# ការគាំទ្រការតាមដានការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តមុខងារជាជម្រើស

ផ្នែកទី៥ "ការគាំទ្រការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តមុខងារជាជម្រើស" នឹងបង្ហាញអំពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនានាក្នុងការគាំទ្រការតាមដានការត្រួតពិនិត្យ និងការវាយតម្លៃលើការ អនុវត្តមុខងារជាជម្រើសដែលក្រុមប្រឹក្សាបានជ្រើសរើស។ អ្នកពាក់ព័ន្ធទាំងនេះអាចធ្វើការសម្របសម្រួល និងស្នើសុំការគាំទ្របច្ចេកទេស សមត្ថភាព និងមធ្យោបាយចាំបាច់ផ្សេងទៀតពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពរបស់រាជរដ្ឋាភិបាល និងពីអ្នកពាក់ព័ន្ធនានាក្នុងការអនុវត្តមុខងារជម្រើសរបស់ខ្លួនដោយផ្ទាល់។

## ៥.១. អ្នកពាក់ព័ន្ធ

អ្នកពាក់ព័ន្ធក្នុង ការគាំទ្រការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តមុខងារជាជម្រើសនេះ រួមមាន ៖

- ក្រុមប្រឹក្សា
- អភិបាល
- មេឃុំ ចៅសង្កាត់
- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា
- អង្គភាពពាក់ព័ន្ធនានា
- គ.ជ.អ.ប
- ដៃគូអភិវឌ្ឍន៍
- សង្គមស៊ីវិល ផ្នែកឯកជន។

## ៥.២. តួនាទី ភារកិច្ច

ក្នុងការគាំទ្រការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តមុខងារជាជម្រើស អ្នកពាក់ព័ន្ធនីមួយៗមានតួនាទី ភារកិច្ចដូចខាងក្រោម ៖

### ៥.២.១. ក្រុមប្រឹក្សា

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ មានតួនាទីតាមដានត្រួតពិនិត្យ និងវាយតម្លៃដំណើរការអនុវត្តមុខងារជាជម្រើសតាមរយៈកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញរបស់ខ្លួន។ ក្រៅពីនេះ ក្រុមប្រឹក្សាក៏អាចចាត់ឱ្យសមាជិករបស់ខ្លួនចុះតាមដានផ្ទាល់នូវការអនុវត្តមុខងារជាជម្រើសផងដែរ។ សមាជិកដែលបានចាត់តាំងត្រូវរាយការណ៍ជូនក្រុមប្រឹក្សាអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តមុខងារជាជម្រើស។

ក្នុងករណី មុខងារជាជម្រើសអនុវត្តដោយក្រុមប្រឹក្សា ក្រុមប្រឹក្សាអាចស្នើសុំការគាំទ្របច្ចេកទេស សមត្ថភាព និងមធ្យោបាយចាំបាច់ផ្សេងៗពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងផ្នែកឯកជននៅក្នុងការអនុវត្តមុខងារជាជម្រើសទាំងនេះ។

ចំពោះមុខងារជាជម្រើស ដែលក្រុមប្រឹក្សាបានជ្រើសរើសត្រូវបានអនុវត្តដោយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងផ្នែកឯកជន ក្រុមប្រឹក្សាគួរផ្តល់ការគាំទ្រ និងសម្របសម្រួលដល់ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងផ្នែកឯកជ ក្នុងការអនុវត្តមុខងារជាជម្រើសទាំងនេះ។

### ៥.២.២. អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវជួយក្រុមប្រឹក្សារបស់ខ្លួនក្នុងការត្រួតពិនិត្យតាមដានលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស។ ការត្រួតពិនិត្យរបស់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវធានាថាមុខងារជាជម្រើសត្រូវបានអនុវត្តស្របតាមបទដ្ឋាននីតិវិធី ពេលវេលា និងលក្ខខណ្ឌផ្សេងៗទៀតដែលបានកំណត់។

អភិបាលរាជធានី ខេត្តត្រូវយកចិត្តទុកដាក់ក្នុងការសម្របសម្រួលឱ្យបានល្អជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានាដើម្បីស្នើសុំការគាំទ្របច្ចេកទេស សមត្ថភាព និងមធ្យោបាយចាំបាច់ផ្សេងទៀតក្នុងការអនុវត្តមុខងារជម្រើសរបស់ខ្លួន។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្របសម្រួល និងស្នើសុំការគាំទ្របច្ចេកទេស សមត្ថភាព និងមធ្យោបាយចាំបាច់ផ្សេងទៀតពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានាក្នុងការអនុវត្តមុខងារជម្រើសរបស់ខ្លួន។ ក្រៅពីនេះ អភិបាលក្រុង ស្រុក ខណ្ឌ ក៏អាចស្នើសុំការគាំទ្រខាងលើនេះពីអភិបាលរាជធានី ខេត្តផងដែរ។

ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលរាជធានី ខេត្តអាចធ្វើប្រតិភូកម្មទៅអភិបាលក្រុង ស្រុក ខណ្ឌ ក្នុងការសម្របសម្រួល និងស្នើសុំការគាំទ្របច្ចេកទេស សមត្ថភាព និងមធ្យោបាយចាំបាច់ផ្សេងទៀតពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានាក្នុងការអនុវត្តមុខងារជាជម្រើស។

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវប្រមូលរបាយការណ៍ជាប្រចាំអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាពីអ្នកពាក់ព័ន្ធក្នុងការអនុវត្តមុខងារជាជម្រើស។ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវតែសង្ខេបលទ្ធផលនៃការពិនិត្យ តាមដានទាំងនេះ ហើយរាយការណ៍ជូនក្រុមប្រឹក្សានៅរៀងរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ ក្រុមប្រឹក្សាអាចធ្វើសេចក្តីសម្រេចដើម្បីដោះស្រាយបញ្ហា ឬអាចធ្វើការណែនាំ និងតម្រង់ទិសឱ្យអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ធ្វើការដោះស្រាយ។

### ៥.២.៣. អង្គភាពជំនាញពាក់ព័ន្ធនានានៅថ្នាក់ក្រោមជាតិ

អង្គភាពជំនាញពាក់ព័ន្ធនានានៅថ្នាក់ក្រោមជាតិ ត្រូវជួយអភិបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ក្នុងការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្ត មុខងារជាជម្រើសដែលអនុវត្តដោយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងផ្នែកឯកជន។

អង្គភាពជំនាញពាក់ព័ន្ធទាំងនោះត្រូវរាយការណ៍អំពីដំណើរការនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសដែលខ្លួនបានអនុវត្ត និងដែលអនុវត្តដោយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងផ្នែកឯកជនជូនអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់។

### ៥.២.៤. គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវពិនិត្យរបាយការណ៍រដ្ឋបាលថ្នាក់ក្រោមជាតិ និងឬរបាយការណ៍វាយតម្លៃផ្សេងៗពាក់ព័ន្ធនឹងការអនុវត្តមុខងារជាជម្រើស ដើម្បីស្វែងយល់អំពីប្រភេទមុខងារជាជម្រើស វឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តមុខងារជាជម្រើសទាំងនោះ។ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ និងអ្នកពាក់ព័ន្ធ ផ្សេងទៀត ក្នុងការគាំទ្របច្ចេកទេស សមត្ថភាព និងមធ្យោបាយចាំបាច់ផ្សេងៗទៀត។

### ៥.២.៥. ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន

ក្នុងការអនុវត្តមុខងារជាជម្រើស ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ អាចស្នើសុំការគាំទ្របច្ចេកទេស សមត្ថភាព និងមធ្យោបាយចាំបាច់ផ្សេងៗទៀត ពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន ដែលមាននៅក្នុង និងក្រៅដែនដីនៃរដ្ឋបាលរបស់ខ្លួន តាមការចាំបាច់។

# ផ្នែកទី ៦

## បទពិសោធន៍នៃការអនុវត្តមុខងារជាជម្រើសនៅប្រទេសកម្ពុជា

បទពិសោធន៍នៃការអនុវត្តមុខងារជាជម្រើសនៅប្រទេសកម្ពុជាអាចមានច្រើន ប៉ុន្តែផ្នែកទី៦នេះ បង្ហាញនូវបទពិសោធន៍ជាក់ស្តែងចំនួនពីរករណីស្តីពីការអនុវត្តមុខងារជាជម្រើស សម្រាប់ឱ្យក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធនានាស្វែងយល់។

បទពិសោធន៍ទាំងពីរនេះ រួមមាន ៖

- ទីមួយ៖ បទពិសោធន៍ទាក់ទងនឹងការគ្រប់គ្រង សត្វពាហនៈ ដើម្បីបង្ការការបំផ្លិចបំផ្លាញដំណាំ និង
- ទីពីរ៖ បទពិសោធន៍ ទាក់ទងនឹងការរៀបចំសណ្តាប់ធ្នាប់ផ្សារព្រែកកញ្ជ្រោងនៅស្រុកឯកភ្នំ។

### ៦.១. បទពិសោធន៍ទីមួយ ÷ ការគ្រប់គ្រងសត្វពាហនៈដើម្បីបង្ការការបំផ្លិចបំផ្លាញដំណាំ

ក្នុងឃុំមួយនៃស្រុកវារិន្ទ ខេត្តសៀមរាប ប្រជាពលរដ្ឋបានជួបប្រទះបញ្ហាការបំផ្លិចបំផ្លាញផលដំណាំ ដោយសារការលែងសត្វពាហនៈបែបអាណាធិបតេយ្យ។ ប្រជាពលរដ្ឋបានប្តឹងតវ៉ាករណីនេះទៅអាជ្ញាធរមូលដ្ឋានដើម្បីស្វែងរកដំណោះស្រាយ។

តាមរយៈការតវ៉ារបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំបានរៀបចំការពិភាក្សាជាមួយម្ចាស់សត្វពាហនៈ និងម្ចាស់ដំណាំ ដើម្បីសម្រុះសម្រួល និងដោះស្រាយបញ្ហាសត្វពាហនៈបំផ្លាញដំណាំ។

ដើម្បីទប់ស្កាត់កុំឱ្យបញ្ហានេះកើតមានបន្តទៀត ក្រុមប្រឹក្សាឃុំ

បានផ្ដួចផ្ដើមគំនិតក្នុងការគ្រប់គ្រងការលែងសត្វពាហនៈទាំងនេះដោយការដាក់ចេញដីកាស្ដីពីការគ្រប់គ្រងសត្វពាហនៈ ដើម្បីបង្ការការបំផ្លិចបំផ្លាញដំណាំរបស់ប្រជាពលរដ្ឋក្នុងឃុំ។

| |
|---|
| **កំណត់សម្គាល់៖** ក្រុមប្រឹក្សាអាចពិភាក្សា និងរៀបចំដីកានេះនៅក្នុងកិច្ចប្រជុំសាមញ្ញរបស់ខ្លួន ហើយការរៀបចំដីកានេះត្រូវការចំណាយថវិកាមួយចំនួនដូចជា ការរៀបចំឯកសារ អាហារសម្រន់ និងប្រើប្រាស់ឧបករណ៍បំពងសម្លេងជាដើម។ |

បន្ទាប់ពីរៀបចំសេចក្ដីព្រាងដីការួចមក ក្រុមប្រឹក្សាបានរៀបចំការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលពាក់ព័ន្ធ ដើម្បីផ្ដល់ឱកាសដល់ពួកគាត់ផ្ដល់យោបល់លើបញ្ញត្តិនានា ដូចជាវិធាន និងការកំណត់ប្រាក់ពិន័យដែលមានចែងនៅក្នុងសេចក្ដីព្រាងដីកានោះ។

បន្ទាប់ពីធ្វើការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋពីសេចក្ដីព្រាងដីការួចហើយ ក្រុមប្រឹក្សាឃុំ បានប្រមូលនូវមតិយោបល់ទាំងនេះមកប្រជុំពិភាក្សាសម្រេចក្នុងកិច្ចប្រជុំរបស់ខ្លួន។ បន្ទាប់ពីក្រុមប្រឹក្សាឃុំបានអនុម័តលើសេចក្ដីព្រាងដីកានេះ មេឃុំជាអ្នកចុះហត្ថលេខាលើដីកា។ ដើម្បីឱ្យប្រជាពលរដ្ឋក្នុងឃុំនោះយល់កាន់តែច្បាស់ថែមទៀតអំពីបទបញ្ញត្តិ នានាដែលមានចែងក្នុងដីកាស្ដីពីការគ្រប់គ្រងសត្វពាហនៈ ដើម្បីបង្ការការបំផ្លិចបំផ្លាញដំណាំរបស់ប្រជាពលរដ្ឋក្នុងឃុំ មេឃុំ បានចាត់ចែងផ្សព្វផ្សាយដីកានេះតាមគ្រប់មធ្យោបាយផ្សេងៗ ដែលមាននៅក្នុងឃុំ។

បន្ទាប់ពីផ្សព្វផ្សាយដីកាស្តីពីការគ្រប់គ្រងសត្វពាហនៈ ដើម្បីបង្ការការបំផ្លិចបំផ្លាញដំណាំរបស់ប្រជាពលរដ្ឋក្នុងឃុំ ក្រុមប្រឹក្សាឃុំបានបង្កើតគណៈកម្មការមួយដើម្បីអនុវត្តដីកានេះ។

### ៦.២. បទពិសោធន៍ទីពីរ ÷ ការរៀបចំសណ្តាប់ធ្នាប់ផ្សារព្រែកកព្រែង ស្រុកឯកភ្នំ ខេត្តបាត់ដំបង

នៅភូមិព្រែកតាច្រែង ឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង អាជីវករដែលបានបោះទីតាំង និងលក់ដូរលើចំណីថ្នល់នៃកំណាត់ផ្លូវខេត្តត្រូវបានប្តូរទីតាំងទៅលក់ដូរនៅលើដីឯកជនមួយកន្លែងជាបណ្តោះអាសន្នរហូតដល់អាជ្ញាធររៀបចំផ្សារទីប្រជុំជនស្រុកបានរួចជាស្ថាពរ។ ក្នុងអំឡុងពេលលក់ដូរនៅទីតាំងបណ្តោះអាសន្ននេះ ការលក់ដូរគ្មានសណ្តាប់ធ្នាប់ របៀបរៀបរយ សោភ័ណភាព និងអនាម័យ ហើយបានបង្កការកកស្ទះចរាចរណ៍ដល់អ្នកធ្វើដំណើរ ពិសេសនៅពេលព្រឹក។ ជារៀងរាល់ថ្ងៃ ប្រជាពលរដ្ឋដែលរស់នៅទីនោះបានរិះគន់ និងលើកបញ្ហានេះជម្រាបប្រាប់សមាជិកក្រុមប្រឹក្សាស្រុកដើម្បីចាត់វិធានការ និងដោះស្រាយ។

តាមរយៈការលើកឡើង និងការរិះគន់របស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាស្រុកក៏បានលើកយកបញ្ហានេះ ទៅពិភាក្សាក្នុងកិច្ចប្រជុំសាមញ្ញប្រចាំខែរបស់ក្រុមប្រឹក្សាស្រុក។

ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ក្រុមប្រឹក្សាស្រុកក៏បានផ្តួចផ្តើមគំនិតក្នុងការគ្រប់គ្រងរៀបចំសណ្តាប់ធ្នាប់កន្លែងលក់ដូរនានារបស់អាជីវករ ឱ្យមានរបៀបរៀបរយ មានសោភ័ណភាព និងអនាម័យល្អ តាមរយៈការដាក់ចេញនូវសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារ

បណ្ណាល័យ
គ.ជ.អ.ប

រៀបចំសណ្តាប់ធ្នាប់ទីប្រជុំជនស្រុក។ បន្ទាប់ពីក្រុមប្រឹក្សាបានអនុម័តសេចក្តីសម្រេចរួចមក គណៈអភិបាលបានសហការជាមួយក្រុមប្រឹក្សាឃុំ និងក្រុមការងារដើម្បីធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងអាជីវករនៅទីប្រជុំជនផ្សារព្រែកតាប្រែងឱ្យបានយល់ដឹងពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាស្រុកក្នុងការរៀបចំសណ្តាប់ធ្នាប់ផ្សារព្រែកតាប្រែងឡើងវិញ តាមរយៈឧគ្ឃោសនៈសព្ទ និងបិទផ្សាយសេចក្តីសម្រេចនៅលើក្តារព័ត៌មាន និងនៅតាមតូបលក់ដូរនៅក្នុងផ្សារព្រែកតាប្រែងរយៈពេលបីថ្ងៃ។

មួយសប្តាហ៍បន្ទាប់ ក្រុមការងារដែលរួមមាន អភិបាលស្រុក អភិបាលរងស្រុក នាយករដ្ឋបាល និងបុគ្គលិក តំណាងមកពីការិយាល័យផែនការស្រុកឯកភ្នំ តំណាងមកពីការិយាល័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ស្រុកឯកភ្នំ តំណាងមកពីការិយាល័យបរិស្ថានស្រុកឯកភ្នំ មេឃុំព្រែកនរិន្ទ តំណាងអាជីវករពីររូប និងតំណាងម្ចាស់ដីឯកជនដែលផ្សារតាំងនៅ ក៏បានចុះរៀបចំសណ្តាប់ធ្នាប់កន្លែងលក់ដូរនៅផ្សារព្រែកតាប្រែងឱ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយល្អ និងអនាម័យបានល្អប្រសើរ និងបានទទួលការពេញចិត្តពីសំណាក់ប្រជាពលរដ្ឋ។ ក្រុមការងារនៅតែបន្តចុះពិនិត្យមើល និងរៀបចំសណ្តាប់ធ្នាប់ផ្សារព្រែកតាប្រែង បន្ទាប់ពីក្រុមការងារបានលើកយកមកពិភាក្សា និងស្នើឱ្យក្រុមប្រឹក្សាសម្រេចក្នុងកិច្ចប្រជុំរបស់ខ្លួន។

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:៧៩៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស ដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១៧១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- យោងតាមសំណើប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**សម្រេច**

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួន សម្រាប់អនុវត្តមុខងារជាជម្រើសរបស់ខ្លួន សំដៅលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងសមធម៌ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីគោលការណ៍ នីតិវិធី និងធនធានសម្រាប់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តនូវមុខងារជាជម្រើសរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តនៅគ្រប់ថ្នាក់រដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសទាំងឡាយណា ដែលមិនស្ថិតនៅក្រោមអាណត្តិនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល ឬមុខងារទាំងឡាយដែលស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា ហើយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានាពុំជំទាស់ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងអនុវត្តនូវមុខងារទាំងនោះ។

អនុក្រឹត្យនេះ មិនគ្របដណ្តប់ទៅលើមុខងារជាជម្រើសដែលរដ្ឋបាលថ្នាក់ក្រោមជាតិបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តបន្តពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល បន្ទាប់ពីក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាលបានផ្ទេរមុខងារទាំងនេះឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

**មាត្រា ៤.-**

វាក្យសព្ទនៅក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ ៖

- **មុខងារ** សំដៅដល់អំពើ ឬសកម្មភាពដែលរាប់បញ្ចូលទាំងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយផ្សេងៗទៀត។
- **មុខងារជាជម្រើស** សំដៅដល់មុខងារទាំងឡាយដែលផ្តួចផ្តើមជ្រើសរើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងក្របខ័ណ្ឌនៃអនុក្រឹត្យនេះ។ មុខងារជាជម្រើសរួមមាន ៖
  + មុខងារទាំងឡាយដែលមិនស្ថិតនៅក្រោមអាណត្តិនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និង
  + មុខងារទាំងឡាយដែលស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល ប៉ុន្តែក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធពុំជំទាស់ចំពោះក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងការអនុវត្តនូវមុខងារទាំងនោះ។

## ជំពូកទី២
## គោលការណ៍

**មាត្រា ៥.-**

ការជ្រើសរើសមុខងារជាជម្រើសរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តផ្អែកតាមគោលការណ៍ដូចខាងក្រោម ៖

- មុខងារដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមានមិនហាមឃាត់
- មុខងារដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងារដែលអាចគ្រប់គ្រង និងអនុវត្តបានប្រកបដោយប្រសិទ្ធភាព ផ្អែកតាមលទ្ធភាព និងធនធានរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងារដែលបម្រើ ឬផ្តល់ផលប្រយោជន៍ជាចម្បងដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

- មុខងារដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ ឬអាទិភាពនៃមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជាពិសេសតម្រូវការរបស់ស្ត្រី យុវជន កុមារ និងជនងាយរងគ្រោះ។

**មាត្រា ៦.-**

បទដ្ឋាន នីតិវិធី និងធនធាន សម្រាប់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស ត្រូវសម្រេចដោយឆន្ទានុសិទ្ធិផ្ទាល់របស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

**មាត្រា ៧.-**

ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស ត្រូវផ្អែកលើគោលការណ៍ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ការពិគ្រោះយោបល់ ការចូលរួម និងសមធម៌។

**ជំពូកទី៣**

**នីតិវិធីនៃការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស**

**មាត្រា ៨.-**

មុខងារជាជម្រើសណាមួយ ឬមួយចំនួន ដែលក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានបំណងជ្រើសរើសយកមកអនុវត្ត ចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលសាមីនីមួយៗ។

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចធ្វើការកែសម្រួលនូវកម្មវិធីវិនិយោគរបស់ខ្លួន ដើម្បីដាក់បញ្ចូលនូវមុខងារជាជម្រើសថ្មី ឬមុខងារជាជម្រើសដែលត្រូវកែសម្រួល ដោយផ្អែកទៅលើសំណូមពរ និងតម្រូវការចាំបាច់របស់មូលដ្ឋាន។

**មាត្រា ៩.-**

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចផ្ដួចផ្ដើមជ្រើសរើសមុខងារជាជម្រើសមកអនុវត្តដោយផ្អែកលើតម្រូវការរបស់ប្រជាពលរដ្ឋ ឬអាទិភាពនៃមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងផ្អែកទៅតាមសមត្ថភាពផ្នែករដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុដែលខ្លួនមាន។

ក្នុងការជ្រើសរើសមុខងារជាជម្រើស ក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទដូចគ្នា និងឬប្រភេទផ្សេងគ្នាដែលពាក់ព័ន្ធតាមការចាំបាច់។

ការសម្រេចយកមុខងារជាជម្រើសណាមួយ ឬមួយចំនួនមកអនុវត្តត្រូវមានការអនុម័តពីក្រុមប្រឹក្សា។

ចំពោះការសម្រេចយកមុខងារជាជម្រើសណាមួយ ឬមួយចំនួនដែលស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្របសម្រួល និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធទាំងនោះ មុននឹងក្រុមប្រឹក្សាអនុម័ត។

**មាត្រា ១០.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ អាចធ្វើការជំទាស់ចំពោះមុខងារ ដែលស្ថិតនៅក្រោមអាណត្តិរបស់ខ្លួន ដែលក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិបានជ្រើសរើស។ ការជំទាស់នេះ ត្រូវធ្វើឡើងជាលាយ

លក្ខណៈអក្សរ ក្នុងអំឡុងពេលនៃដំណើរការកសាង ឬការកែសម្រួលផែនការអភិវឌ្ឍន៍ ឬកម្មវិធីវិនិយោគ។

ការជំទាស់របស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ អាចធ្វើឡើងក្នុងករណី ៖

- បញ្ហាសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស
- មានភាពគ្រួតស៊ីគ្នាជាមួយនឹងផែនការរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត។

**មាត្រា ១១.-**

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស ៖

- ដោយខ្លួនឯងផ្ទាល់ ឬ
- ដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ឬក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ ឬ
- ដោយសហការជាមួយផ្នែកឯកជន ឬសង្គមស៊ីវិល ឬអ្នកពាក់ព័ន្ធនានា។

**មាត្រា ១២.-**

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនត្រូវជានាអនុវត្តនូវមុខងារជាជម្រើសដែលបានអនុម័តដោយក្រុមប្រឹក្សាឱ្យមានប្រសិទ្ធភាព។

**មាត្រា ១៣.-**

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិកែសម្រួល ឬបញ្ឈប់នូវមុខងារជាជម្រើសដែលខ្លួនបានជ្រើសរើសក្នុងការអនុវត្ត។

## ជំពូកទី៤

## ធនធានសម្រាប់អនុវត្តមុខងារជាជម្រើស

**មាត្រា ១៤.-**

ក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តនូវមុខងារជាជម្រើស ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចប្រើប្រាស់ធនធានផ្ទាល់របស់ខ្លួន អំណោយដែលបានមកពីប្រភពខាងក្នុង និងខាងក្រៅដែនសមត្ថកិច្ចរបស់ខ្លួន និងឬចំណូលពីប្រភពផ្សេងទៀតដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តអនុញ្ញាត។

**មាត្រា ១៥.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ អាចប្រមូលកម្រៃពីការប្រើប្រាស់សេវា ដែលពាក់ព័ន្ធនឹងមុខងារជាជម្រើសរបស់ខ្លួន។

ចំណូលដែលប្រមូលបានពីការផ្តល់សេវាដែលពាក់ព័ន្ធនឹងមុខងារជាជម្រើស ជាចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយចំណូលនេះអាចប្រើប្រាស់សម្រាប់រ៉ាប់រងលើការចំណាយមួយផ្នែក ឬទាំងស្រុងនៃការផ្តល់សេវាទាំងនោះ។

តារាងតម្លៃសម្រាប់ការប្រមូលចំណូលពីការប្រើប្រាស់សេវា ដែលពាក់ព័ន្ធនឹងមុខងារជាជម្រើស ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១៦.-**

ការរៀបចំផែនការ ការរៀបចំគម្រោងថវិកា និងនីតិវិធីលទ្ធកម្មពាក់ព័ន្ធនឹងមុខងារជាជម្រើស ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមលិខិតបទដ្ឋាន និងសេចក្តីណែនាំស្តីពីការរៀបចំផែនការ ការរៀបចំគម្រោងថវិកា និងនីតិវិធីលទ្ធកម្មជាធរមាន លើកលែងតែមានលិខិតបទដ្ឋានដោយឡែកសម្រាប់អនុវត្តចំពោះមុខងារជាជម្រើស។

## ជំពូកទី៥

## ការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

**មាត្រា ១៧.-**

ដើម្បីធានាឱ្យការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសប្រកបដោយប្រសិទ្ធភាព គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការគាំទ្របច្ចេកទេស សមត្ថភាព និងមធ្យោបាយចាំបាច់ផ្សេងៗទៀតដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១៨.-**

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចាត់ចែងឱ្យមានការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃទៅលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស។

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវរាយការណ៍អំពីលទ្ធផលនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសជូនក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ១៩.-**

ក្នុងករណីចាំបាច់ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិអាចដាក់ចេញនូវឯកសារបច្ចេកទេស ដើម្បីជួយគាំទ្រដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស។

## ជំពូកទី៦

## អវសានបញ្ញត្តិ

**មាត្រា ២០.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ [illegible] ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**

**នៃព្រះរាជាណាចក្រកម្ពុជា**

សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.-**

**ស ខេង**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

បណ្ណាល័យ
គ.ជ.អ.ប
7